ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២០ លេខ ២៣៨ ខែមីនា ឆ្នាំ ២០២១

ឆ្នាំទី៧០ លេខ ២៣៨ ខែមីនា ឆ្នាំ ២០២១

និពន្ធនាយក :
លោក តាក សុនអ៊ី
គណៈកម្មការនិពន្ធ
១. លោក ខ្សៀវ ណាវី
២. លោក អ៊ឹម សុន្ធរៈ
៣. លោក វង្ស សាវុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
លេខានិពន្ធ
១. លោក ស្វាយ ភីរុណ
២. លោក ម៉ក់ ឈិន
អ្នកបកប្រែភាសា
១. លោកស្រី ម៉ែន នារីសោភ័គ
អ្នកថតរូប
១. លោក សុផាត វីរៈមុនី
វិចិត្រករ
១. លោក ធា សាវុធ
អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
Address :
No 203 Preah
Norodom Bld.
Phnom Penh Cambodia
Tel : 023 219 065



សម្តេចវិបុលសេនាភក្តី សាយ ឈុំ *៖ ប្រមុខរដ្ឋស្តីទី អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតសិង្ហបុរី ចូលជួបសវនាការ និងសម្តែងការគួរសម .....*

៧

សម្តេចតេជោ ហ៊ុន សែន *៖ បើមិនមានការចាំបាច់ទេកុំចេញក្រៅផ្ទះ បើចេញក្រៅផ្ទះត្រូវពាក់ម៉ាស់ .....*

៨



នាយករដ្ឋមន្ត្រី កម្ពុជា ឡាវ និងវៀតណាម ជួបពិភាក្សាគ្នាដើម្បីពង្រឹងទំនាក់ទំនង កិច្ចសហប្រតិបត្តិការប្រទេសទាំងបី .....

១០

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត .....

១១

សម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីវិធាន ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ .....

១២

ក្រមុខ

កម្ពុជាក្នុងយុគសម័យសន្តិភាព និងអភិវឌ្ឍ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចតេជោ ហ៊ុន សែន

មាតិកា Contents

វិចារណកថា : ពង្រឹងកម្លាំងជាតិទាំងមូល រួមគ្នាប្រយុទ្ធយកឈ្នះលើជំងឺកូវីដ-១៩..... ០៣
Editorial : Strengthening Whole National Force in Combatting against Covid-19..... ០៣
- *អត្ថបទនយោបាយ: មជ្ឈដ្ឋានអតតិខាងក្រៅត្រូវបញ្ឈប់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា..... ០៦*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៣*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៧*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ១៩*
- *កម្ពុជាអនុវត្តគោលនយោបាយការបរទេសរឹងមាំ ទន់ភ្លន់ បត់បែន និងការពារផលប្រយោជន៍ ២០*
- *ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីកំណើនសេដ្ឋកិច្ចជាតិក្នុង ២២*
- *វឌ្ឍនភាព និងបញ្ហាប្រឈមនៃវិស័យការងារក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩..... ២៤*
- *អត្ថបទវប្បធម៌: ទំនៀមទំលាប់ក្នុងពិធីបុណ្យចូលឆ្នាំថ្មី..... ២៦*
- *វិទ្យាសាស្ត្រ សុខាភាព: គុណប្រយោជន៍ទាំង១០ នៃសណ្តែកខៀវពិសេសកាត់បន្ថយការឡើង ២៧*
- *កំណាព្យ: អបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ.....សំណើច..... ២៨*

សូមប្រសិទ្ធពរបវរមហាប្រសើរជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៧០ ឈានចូល ៧១ វស្សារបស់សម្តេច

*យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការដឹកនាំប្រទេសឆ្លងកាត់ឧបសគ្គរាប់ម៉ឺនសែនជំពូក ប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាចក្លាហាន តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍រហូតមកដល់បច្ចុប្បន្ននេះ សម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាវិសេសវិសាលបំផុត ដែលបានធ្វើឲ្យប្រទេសជាតិមានសន្តិភាពពេញលេញ ឯកភាពជាតិ ឯកភាពទឹកដី និងមានការអភិវឌ្ឍលើគ្រប់វិស័យប្រជាជនមានសិទ្ធិសេរីភាពបរិបូរនិងរស់នៅយ៉ាងសុខដុមរមនាការពារយ៉ាងរឹងមាំនូវឯករាជ្យ អធិបតេយ្យ និងបូរណភាព ទឹកដី ហើយកំពុងបន្តឈានទៅមុខយ៉ាងស្វាហាប់ លើមាគ៌ាសន្តិភាព និងប្រជាធិបតេយ្យ ឆ្ពោះទៅសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។*

*សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមីនៃវិញ្ញាណក្ខ័ន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមជួយប្រោះព្រំ គាំពារ ថែរក្សា **សម្តេចអគ្គមហាសេនាបតីតេជោ** សម្រេចបានជោគជ័យ ធំៗថ្មីៗទៀត ក្នុងការដឹកនាំប្រទេសកម្ពុជា និងសូមគោរពជូនពរសម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី បានប្រកបនូវពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀងដរាប ។*

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ទស្សនាវដ្តីប្រជាជន

សួស្តីឆ្នាំថ្មី

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥



សូមប្រសិទ្ធពរ បវរសួស្តី សិរីមង្គល មហាប្រសើរ ថ្វាយ និងជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តមអ្នកឧកញ៉ា លោកជំទាវ លោក លោកស្រីមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងជនរួមជាតិនៅគ្រប់ទិសទី ព្រមទាំងអង្គទូត និងអង្គការអន្តរជាតិ នានា ដែលកំពុងបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា សូមបានប្រកបតែនឹង សេចក្តីសុខ រីកចម្រើន ភាពសុខដុមរមនា ត្រជាក់ត្រជុំ ក្រោមម្លប់នៃសុខសន្តិភាព សុភមង្គល និងជោគជ័យជារៀងដរាប ។

គោរពជូនពី

ទស្សនាវដ្តីប្រជាជន

វិចារណកថា EDITORIAL

ពង្រឹងកម្លាំងជាតិទាំងមូល រួមគ្នាប្រយុទ្ធយកឈ្នះលើជំងឺកូវីដ-១៩

Strengthening Whole National Force in Combatting against Covid-19

*នៅក្នុងរយៈពេលជាង ១ឆ្នាំ នៃការប្រយុទ្ធលើសមរភូមិសង្គ្រាមប្រឆាំងនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំលើកកម្ពស់ការជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ខឿនការពារសុខភាពប្រជាជន ដោយបានដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍បន្ទាន់ជាបន្តបន្ទាប់ និងមានប្រសិទ្ធភាព ។ គោលដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល គឺ ការការពារអាយុជីវិតប្រជាជន, ការរក្សាលំនឹងជីវភាពរស់នៅប្រជាជន, ការជួយធ្វើឲ្យធុរកិច្ច និងអាជីវកម្មអាចរស់បាន និងការរក្សាឲ្យបានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ។ អាស្រ័យដោយចំណាត់ការដ៏មានប្រសិទ្ធភាពទាំងនេះហើយ ទើបនៅក្នុងឆ្នាំ២០២០ កន្លងទៅ ដែលជាដំណាក់កាលដ៏លំបាកនៃសង្គ្រាមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាបានភាពម្ចាស់ការលើការងារអាទិភាពចម្បង ២ គឺ **ទី១**-ការបន្តរក្សានូវស្ថិរភាពនយោបាយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងស្ថានការណ៍និង**ទី២**-ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានល្អប្រសើរទប់ស្កាត់អតិផរណា និងការឡើងថ្លៃទំនិញក្នុងទីផ្សារ ។ កម្ពុជាមិនបានស្នើដល់ម្ចាស់បំណុលពន្យាការបង់ប្រាក់កម្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិនោះទេ ។ កម្ពុជានៅតែមានសកម្មភាពដ៏សកម្មក្នុងការបញ្ចេញសាច់ប្រាក់គាំទ្រកម្មវិធីវិនិយោគសាធារណៈ ដូចជា នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅខេត្តព្រះសីហនុ និងខេត្តសៀមរាប ការកសាងផ្លូវ ប្រឡាយទឹក ឬគម្រោងខ្នាតតូចនៅតាមមូលដ្ឋាន និងការអនុវត្តគោលនយោបាយជាតិសង្គមជាដើម ។ រាជរដ្ឋាភិបាលបានត្រៀមកញ្ចប់ថវិកា ១.១៦៤លានដុល្លារ សម្រាប់បម្រុងដោះស្រាយបញ្ហាជំងឺកូវីដ-១៩ និងការស្តារសេដ្ឋកិច្ចជាតិឆ្នាំ២០២០ ដែលមកដល់ពេលនេះ ថវិកានេះត្រូវបានប្រើប្រាស់អស់មួយចំនួនធំហើយ ។ សម្រាប់ឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលបានត្រៀមបម្រុងកញ្ចប់ថវិកាជាង ៨០០លានដុល្លារ ថែមទៀត ដែលសរុបជារួម យើងមានថវិកាជាង ១ពាន់លានដុល្លារ ដើម្បីដោះស្រាយបញ្ហានេះ ។*

*ប៉ុន្តែ «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**» ដែលបានផ្ទុះឡើង បានធ្វើឲ្យមានការប៉ះទង្គិចជាថ្មីយ៉ាងធ្ងន់ធ្ងរបំផុតទៅលើដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ហើយវាបានក្លាយទៅជាបន្ទុកបន្ថែមទៀតសម្រាប់រាជរដ្ឋាភិបាល ក្នុងការប្រកាន់យកជំហរម៉ឺងម៉ាត់ដើម្បីប្រយុទ្ធជាមួយនឹងជំងឺដ៏កាចសាហាវនេះ ។ព្រឹត្តិការណ៍នេះមានលក្ខណៈធ្ងន់ធ្ងរជាងព្រឹត្តិការណ៍សហគមន៍ ៣ វិច្ឆិកា និងព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា ដែលតម្រូវឲ្យប្រជាជនកម្ពុជាត្រូវតែខិតខំយកចិត្តទុកដាក់ និងបង្កើនល្បឿននៃកិច្ចប្រឹងប្រែងរបស់យើងទាំងអស់គ្នាទ្វេឡើងថែមទៀត ដើម្បីបញ្ឈប់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយការចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាព គោរពឲ្យបានពេញលេញការណែនាំនូវវិធានការសុខភាពសាធារណៈទប់ស្កាត់ឲ្យបានការឆ្លងរាលដាលទ្រង់ទ្រាយធំ ។ ក្នុងសភាពការណ៍ដ៏បន្ទាន់នេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្ត*

In more than a year of fighting on the battlefield against Covid-19, the Royal Government of Cambodia has worked hard to promote and protect the public health by launching a series of effective intervening policies and measures. The priority goals of the Royal Government are to protect the lives of the people, to maintain the balance of people's living standard, to stabilize business and commercial activities, and to maintain security, public order and social stability. Thanks to these effective measures, even in the difficult phase of the Covid-19 battle in 2020, the Royal Government of Cambodia maintained leadership over two works of main priority, which are (1) maintaining political stability, the foundation for managing the situation; and (2) maintaining macroeconomic stability, curbing inflation and rising market prices. Cambodia has not asked creditors to defer the payments or its international financial obligations. Cambodia remains active in disbursing cash to support public investment programs, such as in the areas of road infrastructure in Sihanoukville and Siem Reap provinces, the construction of roads, canals or small projects at the local level, and the implementation of national social policies. The Royal Government has prepared a budget of 1.164 million US dollars to solve the problem of Covid-19 disease and the national economic restoration in 2020, a large amount of which has been put to use already. For 2021, the Royal Government has prepared a budget of more than 800 million dollars. In total, we have more than one billion dollars to solve this problem.

However, the "February-20 Community Outbreak" has had the most serious repercussions on the process of Cambodia's socio-economic development and the livelihood of the Cambodian people. It has become an additional burden for the government to pursue firmer stance in fighting this deadly disease. This event is graver than the November-3 community outbreak and the November-28 community outbreak, as it requires the Cambodian people to pay close attention and double the pace of our efforts to stop the spread of Covid-19 by participating effectively and respecting fully the public health measures to prevent such large-scale outbreaks.

In this urgent situation, the Royal Government of Cambodia has paid greater attention to put in place urgent and

ទុកដាក់យ៉ាងខ្លាំងក្នុងការដាក់ចេញនូវវិធានការបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីបញ្ឈប់សការខូចខាតធ្ងន់ធ្ងរ និងដើម្បីជួយរក្សាលំនឹងផលិតកម្មអាជីវកម្ម និងជីវភាពរស់នៅរបស់ប្រជាជន។ វិធានការច្បាប់ត្រូវប្រកាន់យក និងអនុវត្តយ៉ាងម៉ឺងម៉ាត់បំផុត ដើម្បីការពារសុខភាពសាធារណៈរបស់ប្រជាជន ការពារអាយុជីវិតរបស់ប្រជាជន ដោយធានាទប់ស្កាត់មិនឲ្យជំងឺនេះឆ្លងរាលដាលកាន់តែធំរបូតចេញផុតពីការគ្រប់គ្រង ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានដាក់ស្នើសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនឹងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ហើយត្រូវបានរដ្ឋសភាពិភាក្សាអនុម័តយល់ព្រម និងបន្ទាប់មកព្រឹទ្ធសភាក៏បានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុង ហើយត្រូវបានសម្តេចវិបុលសេនាភក្តី ប្រមុខរដ្ឋស្តីទីចុះហត្ថលេខា នៅថ្ងៃទី១១ ខែមីនា ដាក់ឲ្យប្រើប្រាស់ជាបន្ទាន់ ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញអនុក្រឹតស្តីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត លេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិ នៃជំងឺនៅតាមច្រកចេញចូល និងអនុក្រឹតស្តីពីវិធានការចត្តាឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងអនុក្រឹតស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ។ នេះជាឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោ ហ៊ុន សែន** ដើម្បីលើកកម្ពស់ការទទួលខុសត្រូវចំពោះភាពរស់រានមានជីវិតរបស់ប្រជាជននិងការចូលរួមថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងប្រឈមនឹងការគំរាមកំហែងពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។

បច្ចុប្បន្ននេះ កម្ពុជាបានទទួល និងកំពុងប្រើប្រាស់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជាមួយនឹងជំនឿទុកចិត្តខ្ពស់បំផុតក្នុងចំណោមប្រជាជនទូទាំងប្រទេស ព្រមគ្នានឹងការជំរុញយុទ្ធនាការបន្តអនុវត្តនូវវិធានការទាំងឡាយរបស់ក្រសួងសុខាភិបាល ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីការពារសុខភាព និងសុវត្ថិភាពរបស់ខ្លួន សុខមាលភាពរបស់ក្រុមគ្រួសារ របស់សហគមន៍ និងរបស់សង្គមជាតិយើងទាំងមូល ។ ប៉ុន្តែយើងក៏ទទួលស្គាល់ថា ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ បានបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបញ្ហាសុខភាព និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ។ វានៅតែជាហានិភ័យខ្ពស់ បង្កឲ្យមានបញ្ហាធ្ងន់ធ្ងរសម្រាប់រយៈពេលយូរតទៅមុខទៀត ហើយដែលយើងនៅតែមិនអាចប៉ាន់ស្មានបានអំពីទំហំនៃផលវិបាកមកលើសេដ្ឋកិច្ចសង្គម អាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាជន ។ វ៉ាក់សាំងមិនមែនជាដំណោះស្រាយតែមួយគត់នោះទេ ។ វ៉ាក់សាំងអាចជួយកាត់បន្ថយការសម្រាកព្យាបាលនៅមន្ទីរពេទ្យ កាត់បន្ថយមិនឲ្យឈឺធ្ងន់ធ្ងរ ប៉ុន្តែវ៉ាក់សាំងតែមួយមុខមិនអាចបញ្ចប់ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ បានទេ ហើយក៏មិនអាចបញ្ចប់ការផ្ទុះរាលដាលជំងឺនៅពេលបច្ចុប្បន្ននេះបានដែរ ។ ប៉ុន្តែវ៉ាក់សាំងគឺជាមធ្យោបាយដោះស្រាយជាយុទ្ធសាស្ត្រដែលត្រូវតែគូបផ្សំដោយជៀសមិនបានជាមួយនឹងការអនុវត្តន៍វិធានការសុខាភិបាល ដែលបានដាក់ចេញ ដើម្បីឈានទៅសម្រេចជោគជ័យជាមួយការប្រយុទ្ធប្រឆាំងជាមួយនឹងជំងឺនេះ ។ ក្នុងស្មារតីនេះយើងត្រូវរួមគ្នាអនុវត្តឲ្យបានជោគជ័យនូវរាល់បណ្តាភារកិច្ចសំខាន់ៗនោះគឺ ការអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ **«៣កុំ»** គឺ កុំទៅកន្លែងដែលមានមនុស្សកុះករ កុំទៅកន្លែងបិទជិត

effective measures to divert serious damages and to help balance the business and production, and the people's living standard. The Royal Government has taken and strictly enforced legal measures to protect the public health and the lives of the people by ensuring that the disease will not spread further out of control. In this spirit, the Royal Government has submitted a draft Law on Measures to Prevent the Spread of COVID-19, and Highly Contagious Diseases. It has been discussed and approved by the National Assembly, and then by the Senate with unanimous support and were immediately signed by Acting Head of State Samdech Vibol Sena Pheakdey on March 11 with an immediate effect.

The Royal Government of Cambodia issued sub-decrees on the amendment of Article 8 of Sub-Decree No. 129, dated 17 September 2015, regarding the Measures to Prevent and Respond to International Outbreak of Diseases at Gateways; on the Quarantine Measures to Prevent the Spread of Covid-19, and on Health Measures to Prevent the Spread of COVID-19 and Highly Contagious Diseases. This has reflected the strong will of the Royal Government of Cambodia under the leadership of Samdech Techo Hun Sen to uplift responsibility for the people's survival and to take part in maintaining security and public order in the circumstances where our country is facing threat from the spread of Covid-19 disease.

Currently, Cambodia has received and is using the Covid-19 vaccine with the highest trust among the people throughout the country, and at the same time, promoting the campaign to further the measures of the Ministry of Health with high responsibility to protect people's health and safety, the well-being of families, communities and our society as a whole. However, we also recognize that this outbreak of Covid-19 has had a negative impact on people's health and daily lives. It remains a high risk causing severe problems for a long time, and we still cannot estimate the magnitude of the consequence it has on socioeconomics, life and well-being of the people. Vaccines are not the only solution. Vaccines can reduce hospitalization for treatment and the risk of serious illness, but the vaccine alone will not end the Covid-19 transmission, nor can it end the current pandemic. However, vaccines are a strategic solution that must combine inevitably with the implementation of the established health measures to achieve success in the fight against the disease.

In this spirit, we must work together to successfully implement important tasks, that are, to consistently implement the principle of "3 don'ts" - don't go to crowded places, don't go to enclosed places and don't hug each other, and "3 dos" - wearing a mask, washing hands thoroughly and

និងកុំខ្ចិលរឹតគ្នា និង «៣ការពារ» គឺ ត្រូវពាក់ម៉ាស់ លាងដៃឲ្យស្អាត និងរក្សាគម្លាតឲ្យបានយ៉ាងតិចមួយម៉ែត្រកន្លះ ។ ជាមួយគ្នានេះ យើងទាំងអស់គ្នាក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ សម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមគ្រូពេទ្យ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់ផ្នែក និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានលះបង់ពេលវេលា និងបញ្ចេញអស់នូវកម្លាំងកាយ កម្លាំងចិត្ត ក្នុងការធ្វើពលិកម្មដ៏អង់អាច ដើម្បីជួយសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា ក្នុងសមរភូមិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះសប្បុរសជនទាំងឡាយដែលបានជួយឧបត្ថម្ភគាំទ្រជាសម្ភារៈ ថវិកា និងជាស្មារតី ដើម្បីជួយសម្រាលបន្ទុករបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដែលសកម្មភាពនេះបានឆ្លុះបញ្ចាំងឲ្យឃើញនូវស្មារតីមហាសាមគ្គីជាតិដ៏ទូលំទូលាយយ៉ាងក្រៃលែងរបស់ជាតិយើងទាំងមូល ដែលជាប្រពៃណីយូរអង្វែងមកហើយ ។ការជួយឧបត្ថម្ភពីសហគមន៍អន្តរជាតិក៏ដូចជាបណ្តាប្រទេសជាមិត្តក៏បានរួមចំណែកយ៉ាងសំខាន់ក្រៃលែងសម្រាប់កម្ពុជាក្នុងការជម្នះស្ថានភាពដ៏លំបាកនេះ ។

រាជរដ្ឋាភិបាលកម្ពុជាខិតខំប្រឹងប្រែងបន្តជំរុញអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយបរិយាប័ន្ន ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ។ ជំរុញការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព និងបន្តជំរុញអនុវត្តបណ្តាវិធានការគោលនយោបាយសំខាន់ៗផ្សេងទៀតដើម្បីរក្សាស្ថិរភាពជីវភាពប្រជាជនតាមគន្លងប្រក្រតីកម្មថ្មី ដោយបន្តជួយឧបត្ថម្ភគាំទ្រ ដោះស្រាយនូវរាល់ការលំបាកជូនដល់ប្រជាជនក្រីក្រ ជនងាយរងគ្រោះ ធ្វើយ៉ាងណាឲ្យជីវភាពប្រជាជនមានលំនឹងជាមូលដ្ឋាន គ្មានប្រជាជនណាម្នាក់ត្រូវរងគ្រោះដាច់ស្បៀងអាហារ ដោយគណបក្ស និងរាជរដ្ឋាភិបាលមិនបានដឹង និងមិនបានជួយដោះស្រាយនោះឡើយ ។ជំរុញលើកទឹកចិត្តការបង្កបង្កើនផលក្នុងវិស័យកសិកម្ម ដើម្បីគាំទ្រដល់ផលិតកម្មកសិកម្ម សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញទៅទីផ្សារក្រៅប្រទេស ។ លើកទឹកចិត្តឲ្យក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុទាំងអស់ជួយដោះស្រាយបញ្ហាសម្ភាធហិរញ្ញវត្ថុរបស់ប្រជាជន ជាអ្នកទិញអចលនវត្ថុនៅតាមបុរី និងអគារសហគម្មសិទ្ធនានា ពិនិត្យអំពីលទ្ធភាពបន្ធូរបន្ថយលក្ខខណ្ឌបង់រំលោះ លើកលែងការផាក ពិន័យ មិនត្រូវមានបន្ទុកការប្រាក់ ឬជាប់ពិន័យបន្ថែមចំពោះអតិថិជនរហូតដល់ដំណាច់ខែមីនា ។

នៅលើសមរភូមិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នេះ ប្រជាជនកម្ពុជាទូទាំងប្រទេសនៅតែមានជំនឿទុកចិត្តយ៉ាងមុតមាំទៅលើសមត្ថភាពដឹកនាំរបស់រាជរដ្ឋាភិបាល និងការរួបរួមគ្នាជាមហាកម្លាំងជាតិទាំងមូល ចូលរួមអនុវត្តនូវវិធានការទាំងឡាយ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ បន្តពង្រឹងស្មារតីប្រុងប្រយ័ត្នខ្ពស់គ្រប់វិនាទី គ្រប់ដង្ហើមចេញចូល គ្រប់ទីកន្លែង ដោយប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត យកឈ្នះឲ្យបានលើរាល់បញ្ហាប្រឈមទាំងឡាយចំពោះមុខ ក្នុងសង្គ្រាមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដ៏កាចសាហាវ ៕

keeping a distance of at least one and a half meters. At the same time, we would like to express our deep gratitude, appreciation and high evaluation on the efforts of the doctors, competent authorities at all levels, and all stakeholders who have dedicated their times and energy, physical and mental courage to make brave sacrifices to save the lives of Cambodians in the battle against Covid-19. We also would like to express our deepest gratitude to all the donors who have provided material, financial and spiritual supports to lessen the Royal Government's burden in the fight against Covid-19. It has reflected the spirit of extensive and great national solidarity of the entire nation, which is a long-standing tradition. The support of the international community as well as those of our friends have made a significant contribution to Cambodia in overcoming this difficult situation.

The Royal Government of Cambodia further strives to promote sustainable socioeconomic development in order to achieve the goals of sustainable development. It promotes the implementation of a sustainable and effective national social security protection policy and other important policy measures to maintain the stability of people's lives in the new normal way by continuing support and solving all difficulties of the poor and vulnerable. All this is to make sure that that people's lives are stable, and no one is suffering from food shortages without the knowledge and help of the party and the government. The Royal Government encourages agricultural production to support the supply for domestic demand and for export to foreign markets. It also encourages all real estate developers to help solve the financial pressure on the people who buy real estate in satellite cities and condominiums, through identifying the possibility of easing the installment terms, exception for fines, no interest or additional penalties for customers until the end of March.

On the battlefield against Covid-19, Cambodians throughout the country still have strong faith in the leadership of the Royal Government and the unity of the entire national force to implement all the measures set by the Royal Government with high responsibility. They continue to be vigilant and cautious every second, every breath, every place, by putting every physical and mental effort to overcome all the challenges ahead in the war against such dangerous and fierce Covid-19 disease./.

សម្តេចតេជោ ហ៊ុន សែន ៖ សូមបងប្អូនជនរួមជាតិអនុវត្តតាមវិធានសុខាភិបាលឲ្យបានម៉ឺងម៉ាត់ និងបន្តចូលរួមជាមួយវិធានការ «៣ការពារ ៣កុំ» ឱ្យបានម៉ឺងម៉ាត់ជាទីបំផុត

មជ្ឈដ្ឋានអគតិខាងក្រៅត្រូវបញ្ឈប់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងសុខសន្តិភាពពេញលេញ មានការអភិវឌ្ឍលើគ្រប់វិស័យ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ កាន់តែត្រូវពង្រឹងពង្រីកជាមួយនឹងលំហានយោបាយ និងសិទ្ធិសេរីភាពគ្រប់យ៉ាងនៅក្នុងសង្គម ត្រូវបានការពារ និងលើកស្ទួយ។ ប៉ុន្តែពួកប្រឆាំងផ្តាច់មុខដែលជាជនក្បត់ជាតិ ក្បត់ប្រជាជន ដោយមានការគាំទ្រពីមជ្ឈដ្ឋានអគតិខាងក្រៅនៅតែឆ្លៀតប្រើប្រាស់ឧបាយកលទុច្ចរឹតតាមរយៈការប៉ុនប៉ងធ្វើបដិវត្តន៍ពណ៌ ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ ពួកនេះនៅតែបន្តធ្វើការឃោសនាមួលបង្កាច់ការពិតអំពីបញ្ហាប្រជា - ធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ រួមទាំងបញ្ហាផ្សេងៗដទៃទៀត មកធ្វើជាលេសវាយប្រហាររាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា។

ជាក់ស្តែង កាលពីថ្ងៃទី៥ ខែមីនា ក្រោយពេលដែលតុលាការរាជធានីភ្នំពេញ ប្រកាសសាលក្រមកាត់ទោសទណ្ឌិត សម រង្ស៊ី មេដឹកនាំចលនាឧទ្ទាមក្រៅច្បាប់ ព្រមទាំងបក្ខពួកមួយចំនួនដែលត្រូវចោទប្រកាន់ពីបទ «**ឧប ឃាត**» ពាក់ព័ន្ធការប៉ុនប៉ងធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ក្រោមឧបាយកលជាផែនការនៃការវិលត្រឡប់ចូលប្រទេសកម្ពុជា អំឡុងព្រឹត្តិការណ៍ ៩ វិច្ឆិកា ២០១៩ ក៏មានជនបរទេសមួយចំនួនតាំងខ្លួនធ្វើជាចៅក្រមក្រៅច្បាប់ លូកដៃចូលមកអារកាត់កិច្ចការផ្ទៃក្នុងរបស់តុលាការ នៃរដ្ឋអធិបតេយ្យរបស់កម្ពុជា ។ គេបានលើកឡើងពីរបស់ដែលហៅថា ការរួមតូចនៃលំហសេរីភាព និងប្រជាធិបតេយ្យនៅកម្ពុជា ដោយឆ្លៀតប្រើប្រាស់ពាក្យសម្តីមិនត្រឹមត្រូវវាយប្រហារទៅលើតុលាការរបស់កម្ពុជា ។ ប៉ុន្តែលើភាពជាក់ស្តែង ដំណើរការរបស់តុលាការទៅលើសំណុំរឿងជនជាប់ចោទ សម រង្ស៊ី និងបក្ខពួក គឺផ្អែកទៅលើភស្តុតាងរឹងមាំជាក់ស្តែង ស្របតាមនីតិវិធីត្រឹមត្រូវ។ នីតិវិធីរបស់តុលាការបានប្រព្រឹត្តិទៅស្របតាមច្បាប់ដោយមានតម្លាភាព និងមានការចូលរួមពីមេធាវីការពារជនជាប់ចោទ តំណាងអង្គទូតបរទេស និងអង្គការសង្គមស៊ីវិល ដូចដែលប្រទេសប្រជាធិបតេយ្យទាំងអស់នៅលើពិភពលោកបាននិងកំពុងអនុវត្ត ។ ម៉្យាងវិញទៀត នៅក្នុងដំណើរការនៃសវនការនេះតុលាការ ក៏បានរកឃើញថា សម រង្ស៊ី និងបក្ខពួកពិតជាមានពិរុទ្ធភាពជាក់ស្តែង ដោយពួកនេះបានអនុវត្តផែនការដ៏គ្រោះថ្នាក់ ធ្វើសកម្មភាពញុះញង់កងទ័ព មន្ត្រីរាជការ និងប្រជាជនឲ្យផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ និងកៀងគរថវិកា ដើម្បីផ្គត់ផ្គង់កម្លាំងខុសច្បាប់ គាំទ្រចលនារបស់ខ្លួន ដែលទង្វើនេះ គឺស្មើនឹងការធ្វើរដ្ឋប្រហារ។ រាល់ទម្រង់នៃការញុះញង់ បំផុសប្រមូលប្រជាជន និងកម្លាំងប្រដាប់អាវុធដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតគឺជាសកម្មភាពខុសច្បាប់ និងប៉ះពាល់ដល់សន្តិសុខរដ្ឋ ជាអំពើឧក្រិដ្ឋ ដែលត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាទីបំផុត ទោះផែនការនេះធ្វើក្នុងទម្រង់ជារដ្ឋប្រហារក្តី ជាកុប្បកម្មក្តី ជាបដិវត្តន៍ដោយហិង្សាក្តី ឬដោយការប្រើអំណាចប្រជាជនតាមរយៈបដិវត្តន៍ពណ៌ក្តី។ ការដណ្តើមអំណាចតាមវិធីណាក៏ដោយ ក្រៅពីតាមរយៈការបោះឆ្នោតតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ជាអំពើខុសច្បាប់ ដែលសមត្ថកិច្ចត្រូវចាត់គ្រប់វិធានការ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបឲ្យខាងតែបាន ។ ដូច្នេះ គម្រោងវិលចូលកម្ពុជាវិញរបស់ សម រង្ស៊ី និងបក្ខពួក គឺជាគម្រោងនៃការធ្វើរដ្ឋប្រហារ ដែលនាំទៅដល់ការបំផ្លាញសុខសន្តិភាព ការបំបែកបំបាក់ជាតិ ដែលអាចបង្កនូវគ្រោះមហន្តរាយធ្ងន់ធ្ងរ មិនអាចប៉ាន់ស្មានបានចំពោះជាតិ និងប្រជាជនកម្ពុជា ។ ត្រូវកំណត់ច្បាស់ថា ការចាត់វិធានការច្បាប់ចំពោះសកម្មភាពទាំងឡាយណា ដែលប៉ុនប៉ងបំផ្លាញសុខសន្តិភាព ស្ថិរភាពនយោបាយ ការញុះញង់ឲ្យមានអំពើហិង្សា ចលនាបំបែកបំបាក់ផ្ទៃក្នុងជាតិឈានទៅផ្តួលរំលំរាជរដ្ឋាភិបាល គឺពុំមែនជាសកម្មភាពរំលោភសិទ្ធិមនុស្សក្នុងសង្គមប្រជាធិបតេយ្យនោះឡើយ។ យើងរំឭកថានៅពេលនោះ សូម្បីអ្នកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានថ្លែងថ្កោលទោស សម រង្ស៊ី នៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីឆ្នាំ២០១៩ ចំពោះសម្តីបរិហារកេរ្តិ៍ និងញុះញង់ឲ្យផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជា ដែលជ្រើសតាំងដោយប្រជាជនកម្ពុជា តាមរយៈការបោះឆ្នោតដែរ ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី១ ខែមីនា តុលាការរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោស សម រង្ស៊ី និងបក្ខពួក ចំនួន ៨នាក់ ឲ្យជាប់ពន្ធនាគារពី ២០ឆ្នាំ ទៅ ២៥ឆ្នាំ ព្រមទាំងដកហូតសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ដោយសារជនទុច្ចរឹតទាំងនេះ បានប្រព្រឹត្តិបទល្មើស ដោយព្រះរាជអាជ្ញាចោទប្រកាន់ពីបទ ឧបឃាត តាមមាត្រា ២៧ និង ៤៥១ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធការប៉ុនប៉ងធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ក្រោមឧបាយកលជាផែនការនៃការវិលត្រឡប់ចូលប្រទេសកម្ពុជា អំឡុងព្រឹត្តិការណ៍ ៩ វិច្ឆិកា ២០១៩ ។

បច្ចុប្បន្ននេះ កម្ពុជានៅតែប្រកាន់ខ្ជាប់គោលជំហរដ៏មុតមាំ ក្នុងការធានា និងការពាររដ្ឋធម្មនុញ្ញ ការពារប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ឲ្យកាន់តែរឹងមាំ ស្របតាមនិន្នាការរីកចម្រើនជាក់ស្តែងរបស់សង្គមជាតិ និងការថែរក្សាសុខសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ ការធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ប្រជាជន និងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យកាន់តែមានការរីកចម្រើន ។ ពួកមជ្ឈដ្ឋានអគតិមួយចំនួនដែលនៅតែប៉ុនប៉ងបំផ្លាញសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា ក៏ត្រូវតែបញ្ឈប់រាល់ការជ្រៀតជ្រែកលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយរួមចំណែកជាមួយកម្ពុជាក្នុងការកសាង និងធ្វើឲ្យកម្ពុជាកាន់តែមានការរីកចម្រើនលូតលាស់នូវលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងការពង្រឹងនីតិរដ្ឋបន្តទៅមុខទៀត ៕

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី អនុញ្ញាតឲ្យ ឯកអគ្គរដ្ឋទូតសិង្ហបុរីចូលជួបសវនាការ និងសម្តែងការគួរសម

*សម្តេចភក្តី សាយ ឈុំ អនុញ្ញាតឱ្យលោកជំទាវ **ចាវ ឡេង ឈិង** ចូលជួបធ្វើសវនាការ និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៥ ខែមីនា ឆ្នាំ២០២១ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកជំទាវធាវ ឡេ ឈិង (TeoLayCheng) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសិង្ហបុរីថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបធ្វើសវនាការ និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុង**ព្រះបរមនាម ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** បានសម្តែងនូវការអបអរសាទរជូនចំពោះលោកជំទាវ **ចាវ ឡេងឈិង** ដែលត្រូវបានតែងតាំង ជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសិង្ហបុរីប្រចាំព្រះរាជាណាចក្រកម្ពុជា។ តាមរយៈបេសកកម្មការទូតនេះ សម្តេចមានជំនឿជឿជាក់ថា លោកជំទាវឯកអគ្គរដ្ឋទូត នឹងខិតខំលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងកម្ពុជា និងសិង្ហបុរី ឱ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេង សម្រាប់ប្រជាជននៃប្រទេសទាំងពីរទាំងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។ សម្តេចប្រមុខរដ្ឋស្តីទីកម្ពុជា បានរំលឹកអំពីទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ ដែលបានភ្ជាប់ទំនាក់ទំនងការទូត កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៦៥។ កាលពីឆ្នាំ២០២០ ប្រទេសទាំងពីរបានប្រារព្ធពិធីអបអរសាទរខួបលើកទី៥៥ នៃចំណងការទូត តាមរយៈការរៀបចំព្រឹត្តិការណ៍បង្ហាញគំនូរ សិល្បៈ ម្ហូបអាហារ តន្ត្រី និងវប្បធម៌របស់ប្រទេសទាំងពីរ។ កត្តានេះ បានបង្ហាញឱ្យឃើញពីទំនាក់ទំនងកាន់តែរឹងមាំ និងស៊ីជម្រៅរវាងប្រជាជន និងប្រទេសទាំងពីរ។

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទីកម្ពុជា បានមានប្រសាសន៍ថា ទោះបីជាស្ថិតក្នុងវិបត្តិ នៃជំងឺកូវីដ-១៩នេះក្តី ក៏ពាណិជ្ជកម្មទ្វេភាគីរបស់ប្រទេសទាំងពីរ មានទំហំ ៤,២៤ ប៊ីលានដុល្លារអាមេរិក។ ការវិនិយោគរបស់ប្រទេសសិង្ហបុរី នៅព្រះរាជាណាចក្រកម្ពុជា មានទំហំទៅដល់ ១,២៩ ប៊ីលានដុល្លារអាមេរិក (ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០២០)។ សម្តេចភក្តីបានស្នើដល់ឯកអគ្គរដ្ឋទូត ជួយជំរុញការធ្វើវិនិយោគ និងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដើម្បីរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម របស់ប្រទេសទាំងពីរ ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩។ សម្តេចបានវាយតម្លៃខ្ពស់ចំពោះប្រទេសសិង្ហបុរី ដែលមានប្រព័ន្ធអប់រំល្អ និងស្នើឯកអគ្គរដ្ឋទូតថ្មី ពិនិត្យលទ្ធភាពបង្កើនការផ្តល់អាហារូបករណ៍របស់ប្រទេសសិង្ហបុរីឱ្យនិស្សិត និងមន្ត្រីរាជការកម្ពុជាបន្ថែមទៀត ។

សម្តេចវិបុលសេនាភក្តី សាយ ឈុំ បានបង្ហាញនូវសេចក្តីពេញចិត្ត និងវាយតម្លៃខ្ពស់ ចំពោះទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ ការរីកចម្រើន និងទំនាក់ទំនងដ៏ល្អនេះ ស្តែងឡើង តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្នាទៅវិញទៅមក រវាងថ្នាក់ដឹកនាំកំពូល ថ្នាក់ដឹកនាំជាន់ខ្ពស់ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ក៏ដូចជាស្តែងឡើងតាមរយៈនៃការគាំទ្រគ្នាទៅវិញទៅមក ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ។ ក្នុងនាមប្រជាជនកម្ពុជា សម្តេចវិបុលសេនាភក្តី បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលសិង្ហបុរី ដែលបានរួមវិភាគទានយ៉ាងច្រើនក្នុងការកសាងអភិវឌ្ឍប្រទេសកម្ពុជា តាមរយៈគម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគី និងបានជួយពង្រឹងសមត្ថភាពមន្ត្រីរាជការកម្ពុជាលើជំនាញនានា នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-សិង្ហបុរី។

ក្នុងឱកាសជួបសវនាការនោះ លោកជំទាវ **ចាវ ឡេងឈិង** បានវាយតម្លៃខ្ពស់ ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងប្រទេសទាំងពីរ ក្នុងវិស័យជាច្រើនដូចជា៖ វិស័យសេដ្ឋកិច្ច វិស័យសុខាភិបាល ក៏ដូចជាទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ។ វិស័យសេដ្ឋកិច្ច និងការវិនិយោគរវាងប្រទេសទាំងពីរ មានការកើនឡើងជាលំដាប់ ជាពិសេសអ្នកវិនិយោគិនសិង្ហបុរី បានសហការយ៉ាង ជិតស្និតជាមួយនឹងអ្នកវិនិយោគកម្ពុជា ក្នុងការអភិវឌ្ឍលើកកម្ពស់វិស័យបច្ចេកវិទ្យា និងវិស័យឌីជីថលជាពិសេសវិស័យទេសចរណ៍ និងវិស័យបដិសណ្ឋាកិច្ច។ រីឯការហោះហើរត្រង់ពីប្រទេសសិង្ហបុរី មកព្រះរាជាណាចក្រកម្ពុជា គឺមានការកើនឡើង ៩ដងក្នុងមួយ សប្តាហ៍ដែលអាចជំរុញលើកកម្ពស់ទំនាក់ទំនង និងការផ្សារភ្ជាប់រវាងប្រជាជននៃប្រទេសទាំងពីរ។ ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគី ប្រទេសទាំងពីរក៏មានកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយនឹងគ្នាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិផងដែរ។

នាពេលខាងមុខនេះ សភាកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) លើកទី១១ នៅពាក់កណ្តាល ឬចុងខែតុលា ឆ្នាំ២០២១ និងមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅឆ្នាំ២០២២ ក្នុងឱកាសនោះ សម្តេចវិបុលសេនាភក្តីក៏បានស្នើសុំការគាំទ្រ និងអញ្ជើញសភាសិង្ហបុរី ចូលរួមក្នុងកិច្ចប្រជុំទាំងនេះផងដែរ៕

សម្តេចតេជោ ហ៊ុន សែន ៖ បើមិនមានការចាំបាច់ទេ កុំចេញក្រៅផ្ទះ បើចេញក្រៅផ្ទះត្រូវពាក់ម៉ាស់

❋ សម្តេចតេជោ ហ៊ុន សែន ជំរុញឲ្យចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ឲ្យបាន ១លានដូសក្នុង១ខែ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញធ្វើសន្និសីទសារព័ត៌មានជុំវិញការវិវឌ្ឍន៍ថ្មីៗ នៃស្ថានភាពជំងឺកូវីដ-១៩ និងការប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩

❋

នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ក្រោយពីទទួលបានវ៉ាក់សាំងរួច **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញធ្វើសន្និសីទសារព័ត៌មានជុំវិញការវិវឌ្ឍន៍ថ្មីៗនៃស្ថានភាពជំងឺកូវីដ-១៩ និងការប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩ ។

សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជាអាចមានលទ្ធភាពក្នុងការទទួលបានជំនួយវ៉ាក់សាំងប្រឆាំងកូវីដឈ្មោះ (Sinopharm) ពីចិនលើសពី១លានដូស ខណៈចំនួន៤០ម៉ឺនដូសបន្ថែម នឹងមកដល់កម្ពុជាមុនចូលឆ្នាំខ្មែរ។ សម្តេចតេជោបានបញ្ជាក់ជាថ្មីអំពីមូលហេតុដែលសម្តេចមិនអាចចាក់វ៉ាក់សាំងស៊ីណូហ្វាមរបស់ចិន ដោយសារតែកត្តាអាយុដែលកំណត់ គឺ១៨ឆ្នាំ ដល់ ៥៩ឆ្នាំ ចំពោះវ៉ាក់សាំងថ្មីឈ្មោះ (AstraZeneca)នេះ មិនមានការកំណត់អាយុនោះទេ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងអំណរគុណដល់ដៃគូអន្តរជាតិនានា ដែលបានជួយសម្រួលសម្រួលក្នុងការផ្តល់ជំនួយវ៉ាក់សាំងដល់ប្រទេសកម្ពុជានាពេលនេះ។ ប្រទេសកម្ពុជា ជាប្រទេសទី១ នៅអាស៊ីប៉ាស៊ីហ្វិក ដែលទទួលបានវ៉ាក់សាំងពីមជ្ឈមណ្ឌលកូវ៉ាក់ (COVAX Facility)។ បន្ថែមពីនេះក៏មានប្រទេសជាមិត្តមួយចំនួនទៀត បានផ្តល់ជាជំនួយថវិកា សម្រាប់ប្រើប្រាស់ក្នុងការទិញវ៉ាក់សាំងប្រឆាំង COVID-19 ដល់រាជរដ្ឋាភិបាលកម្ពុជាថែមទៀត។ កម្ពុជានឹងអាចនឹងទទួលវ៉ាក់សាំង ២០% នៃចំនួនប្រជាពលរដ្ឋពីមជ្ឈមណ្ឌលកូវ៉ាក់ ប៉ុន្តែការទទួលនេះនឹងធ្វើឡើងតាមដំណាក់កាល ដែលឆមាសទី១កម្ពុជានឹងបានជាង១លានដូស និងជំហានបន្តបន្ទាប់ទៀត។ សម្តេចតេជោស្នើឲ្យក្រសួងសុខាភិបាលរៀបចំចាក់វ៉ាក់សាំងឈ្មោះ អាស្ត្រាហ្សេនីកា (AstraZeneca) ជូនប្រជាពលរដ្ឋទូទៅដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ជាពិសេសជំហានដំបូងអាទិភាពសំខាន់ ខេត្ត ក្រុង គោលដៅចំនួនបី គឺរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ដែលជាខេត្តក្រុងប្រឈមនឹងការរីករាលដាលជំងឺកូវីដ-១៩ ទាមទារឲ្យមានការចាក់ជាបន្ទាន់ទៅដល់ប្រជាពលរដ្ឋដែលកំពុងប្រឈមនឹងការឆ្លងជំងឺនេះ ពីព្រោះការរក្សាទុកវ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) មានរយៈពេល១ឆ្នាំ នឹងផុតកំណត់ ចំណែកវ៉ាក់សាំងអាស្ត្រាហ្សេនីកា (AstraZeneca) មានរយៈពេលត្រឹម៩ខែប៉ុណ្ណោះ នឹងហួសពេលកំណត់។ សម្តេចតេជោបានអនុញ្ញាតឱ្យមន្ត្រីទូតដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិលដែលកំពុងបម្រើការងារ និងរស់នៅក្នុងប្រទេសកម្ពុជាអាចទទួលបានវ៉ាក់សាំង Astra Zeneca នៅកម្ពុជាបានដោយមិនមានការគិតថ្លៃអ្វីនោះទេ។ មន្ត្រី និងប្រជាពលរដ្ឋទូទៅដែលមានអាយុចាប់ពី៦០ ឆ្នាំឡើង លើនឹងផ្តល់លទ្ធភាពឱ្យចាក់វ៉ាក់សាំងឈ្មោះ អាស្ត្រាហ្សេនីកា (Astra Zeneca) ចំណែកអ្នកអាយុ៥៩ឆ្នាំចុះក្រោមអនុញ្ញាតឱ្យចាក់វ៉ាក់សាំង ឈ្មោះ ស៊ីណូហ្វាម (Sinopharm) ដោយសារចំនួនវ៉ាក់សាំងមានកម្រិត។

សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា ការចាក់វ៉ាក់សាំងមិនមែនជាដំណោះស្រាយមាស នៅក្នុងការលុបបំបាត់ជំងឺ COVID-19 ចេញពីប្រទេសកម្ពុជានោះទេ ពោលការអនុវត្តនវិធានការ **«៣កុំ និង៣ការពារ»** ទើបអាចជួយកម្ពុជា យកឈ្នះជំងឺ COVID-19 បាន។ សម្តេចថ្លែងថា៖ «វ៉ាក់សាំងមិនមែនជាដំណោះស្រាយមាសតែមួយគត់ទេ ប៉ុន្តែវ៉ាក់សាំងគឺជាមធ្យោបាយដោះស្រាយជាយុទ្ធសាស្ត្រ គឺជាគន្លឹះទីមួយ រួមជាមួយការអនុវត្តនវិធានការសុខាភិបាល ដែលយើងបានដាក់ចេញដូចជា ៣ការពារ និង៣កុំជាដើម។ ការពង្រឹងការត្រួតពិនិត្យច្រកចេញចូលព្រំដែន ការធ្វើតេស្ត ការធ្វើចត្តាឡីស័ក និងការព្យាបាល ទៅក្នុងការប្រយុទ្ធជាមួយជំងឺ COVID-19 ដើម្បីឈានទៅសម្រេចជោគជ័យជាមួយការប្រយុទ្ធប្រឆាំងជាមួយនឹងជំងឺនេះ»។ វិធានការ «**៣កុំ និង៣ការពារ**» រួមមាន៖ ៣កុំ គឺកុំជួបជុំគ្នា កុំនៅក្នុងបន្ទប់បិទជិតហើយប្រើម៉ាស៊ីនត្រជាក់រួម និងកុំចាប់ដៃគ្នា កៀកកើយ ឱបថើបគ្នាជាដើម។ ចំណែកឯវិធានការ ៣ការពារគឺ ពាក់ម៉ាស់ លាងដៃជាមួយសាប៊ូ ឬជែល និងរក្សាគម្លាតសង្គម។ សម្តេចតេជោគូសបញ្ជាក់ថា រហូតមកដល់ពេលនេះ មិនមានប្រភពណាបញ្ជាក់ច្បាស់ថា ការចាក់វ៉ាក់សាំងនឹងមានប្រសិទ្ធភាពការពារក្នុងរយៈពេលណាមួយ ឬ១ជីវិតនោះទេ ដូច្នេះមានតែវិធីការពារអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលតែប៉ុណ្ណោះទើបល្អប្រសើរ។ សម្តេចតេជោថ្លែងថា កម្ពុជាទទួលយកការផ្តត់ផ្តង់វ៉ាក់សាំង១សែនដូសពីឥណ្ឌា ប៉ុន្តែកម្ពុជានឹងស្នើទិញ១លានដូសថែមទៀត នៅខែឧសភាខាងមុខនេះ។ ក្រៅពីវ៉ាក់សាំងស៊ីណូហ្វាម និង អាស្ត្រាហ្សេនីកា កម្ពុជាកំពុងពិនិត្យមើលវ៉ាក់សាំងប្រភេទផ្សេងៗមួយចំនួនទៀត ។ **សម្តេចតេជោ ហ៊ុន សែន** អំពាវនាវដល់ពលរដ្ឋ កុំធ្វើដំណើរចេញចូលខេត្តព្រះសីហនុ បើមិនចាំបាច់នោះទេ។ ពលរដ្ឋខេត្តព្រះសីហនុ កុំចេញឆ្លងខេត្តដទៃទៀតក្នុងមួយរយៈពេលនេះ ដោយសារតែជំងឺកូវីដ-១៩ កំពុងតែមានការឆ្លងជាហូរហែនោះ។ សម្តេចតេជោក៏បានសម្រេចផ្អាកការធ្វើដំណើររបស់ប្រជាពលរដ្ឋទេសចរណ៍ចូលខេត្តព្រះសីហនុប៉ុន្តែការដឹកទំនិញចេញចូលនៅប្រព្រឹត្តដដែល។ ប្រជាពលរដ្ឋនៅភ្នំពេញកុំចេញពីផ្ទះបើសិនជាគ្មានភាពចាំបាច់នោះទេ ដើម្បីចូលរួមទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ទាំងអស់គ្នា។ សម្តេចតេជោក៏បានឯកភាពជាមួយសំណើក្រសួងអប់រំ ឱ្យបិទសាលារៀន នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុមួយរយៈបន្តទៀត។

❋ នៅរាត្រីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានថ្លែងសារពិសេសបន្ទាន់មួយទៅកាន់ជនរួមជាតិទាក់ទងករណីឆ្លងជំងឺកូវីដ-១៩។ សភាពការណ៍នៅក្នុងប្រទេសរបស់យើង ពិតជាមិនធម្មតាដែរហូតមកដល់ម៉ោងនេះការរកឃើញកូវី១៩ចំនួនអ្នកឆ្លងថ្មីរហូតទៅដល់ ៤៩នាក់។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា សភាពការណ៍នេះបានជាក់ចេញជាចំណោទធំៗ សម្រាប់យើងក្នុងការបន្តជំហានដើម្បីប្រយុទ្ធជាមួយនឹងជំងឺដ៏កាចសាហាវនេះ។ សម្តេចតេជោស្នើសុំឲ្យស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាល និងស្ថាប័ននីតិបញ្ញត្តិសុំផ្អាកជាបណ្តោះអាសន្ននូវស្ថាប័ន ប៉ុន្តែយើងក៏ត្រូវមានមនុស្សប្រចាំការ មនុស្សភាគច្រើនត្រូវធ្វើការនៅតាមផ្ទះ ក្នុងរយៈពេលយ៉ាងតិច ៧ថ្ងៃ ធ្វើបានដូច្នេះគឺយើងអាចបញ្ឈៀសបាននូវហានិភ័យដែលយើងមិនទាន់ស្គាល់នូវអ្នកដែលមានការពាក់ព័ន្ធ ព្រោះពិតជាច្របូកច្របល់ខ្លាំងណាស់នៅពេលនេះ។ មានការឆ្លងនៅក្នុងក្របខណ្ឌនគរបាល មន្ត្រីរាជការរហូតដល់សិល្បករ សិល្បការនី។ដូច្នេះការបិទស្ថាប័នជាបណ្តោះអាសន្ននេះមិនមែនជាការបិទទាំងស្រុងទេ ក៏ប៉ុន្តែសុំឱ្យកាត់បន្ថយចំនួនមនុស្សយ៉ាងតិច ៩០% ហើយមានមនុស្សតែមួយចំនួនតូចនៅប្រចាំការធ្វើការនៅតាមស្ថាប័ន។ **សម្តេចតេជោ ហ៊ុន សែន** បានអំពាវនាវដល់ក្រុមគ្រួសារកុំឲ្យកូនៗចេញក្រៅផ្ទះ គ្រប់គ្រងកូននៅក្នុងផ្ទះ។ សម្រាប់មនុស្សចាស់មនុស្សពេញវ័យប្រសិនបើមិនមានការចាំបាច់ទេ គឺកុំចេញក្រៅផ្ទះ ហើយប្រសិនបើចេញក្រៅផ្ទះត្រូវតែពាក់ម៉ាសឲ្យបានហ្មត់ចត់ព្រោះឥឡូវនេះមិនដឹងថាជំងឺ ពិតប្រាកដនៅកន្លែងណា។ នេះគឺជាបញ្ហាប្រឈមដ៏ធំ។ គឺជាវិធានការចាំបាច់ដើម្បីការពារសុខភាពរបស់បុគ្គលម្នាក់ៗ ក៏ដូចជាក្រុមគ្រួសារនីមួយៗព្រមទាំងសង្គមជាតិរបស់យើង។

សម្តេចតេជោ ហ៊ុន សែន បានស្នើប្រធានព្រឹទ្ធសភាស្តីទី មេត្តាពិនិត្យរកវិធីណា ដើម្បីឱ្យច្បាប់ដែលរដ្ឋសភាបានអនុម័តនោះ បានចូលជាធរមាន អាចបើកការប្រជុំតាមអនឡាញ ហើយមានការជួបជុំក្នុងទម្រង់មនុស្សតិច ដែលអាចធ្វើទៅបាន ព្រោះច្បាប់នេះវាត្រូវការបន្ទាន់។ យើងមិនអាចប្រើច្បាប់ក្នុងគ្រាមានអាសន្នសម្រាប់សភាពការណ៍នេះទេ តែយើងត្រូវការច្បាប់គ្រប់គ្រងទាក់ទងនឹងជំងឺកូវីដ-១៩ នឹងជំងឺកាចសាហាវផ្សេងទៀត ។ សម្តេចតេជោ អំពាវនាវសុំផ្អាកការជួបជុំដែលមិនមានការចាំបាច់ និងសុំអរគុណបងប្អូនដែលបានផ្អាកពិធីរៀបអាពាហ៍ពិពាហ៍ ឬក៏ធ្វើពិធីអាពាហ៍ពិពាហ៍ក៏ប៉ុន្តែបន្ថយចំនួនមនុស្ស ដែលធ្វើឱ្យហានិភ័យមានការធ្លាក់ចុះ។ ប៉ុន្តែសភាពការណ៍ពេលនេះទាមទារមានការប្រុងប្រយ័ត្នលើសមុន អ្វីដែលមិនចាំបាច់ និងមិនទាន់ចាំបាច់ និងអាចផ្អាកបានគប្បីត្រូវតែពន្យា រងចាំធ្វើពេលក្រោយក៏មិនទាន់ហួសពេលដែរ។ នេះគឺជាសភាពការណ៍ដែលបន្ទាន់ ហើយដែលត្រូវយកចិត្តទុកដាក់ កុំឲ្យជំងឺនេះសាយភាយចេញក្រៅ។ សម្តេតេជោបានសុំឲ្យខេត្តព្រះសីហនុធ្វើការរឹតបន្តែមទៀត ទៅលើការចេញចូលរបស់មនុស្ស។ ប៉ុន្តែមិនត្រូវធ្វើមានការរាំងស្ទះទៅដល់ការដឹកទំនិញចេញចូលនោះទេ ព្រោះជាច្រកសេដ្ឋកិច្ចតែមួយគត់ របស់យើងសម្រាប់ការនាំចេញតាមផ្លូវទឹក ។ ការធ្វើដំណើរការដឹកជញ្ជូនទំនិញទាំងទំនិញក្នុងប្រទេស និងទំនិញឆ្លងកាត់ព្រំដែន នៅតែត្រូវធ្វើធម្មតាដើម្បីបន្តជំរុញទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ពិសេសគឺពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសយើងជាមួយនឹងប្រទេសជិតខាង ក៏ដូចជាជាមួយប្រទេសយើង និងប្រទេស ដទៃទៀត ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ទៀតថា ការប្រកាសចេញជាបទបញ្ជានេះគឺធ្វើឡើងតែសម្រាប់ស្ថាប័នស៊ីវិលតែប៉ុណ្ណោះ សម្រាប់កងកម្លាំងប្រដាប់អាវុធ ទាំងកងទ័ពទាំងនគរបាល ទាំងអាវុធហត្ថនៅធ្វើប្រតិបត្តិការជាធម្មតា។ ចំពោះក្រុមគ្រូពេទ្យនៅធ្វើប្រតិបត្តិការជាធម្មតា។ ការកាត់បន្ថយចំនួនមនុស្សធ្វើការនៅតាមស្ថាប័ននេះ គឺមិនសំដៅទៅរកកងកម្លាំងប្រដាប់អាវុធ និងក្រុមគ្រូពេទ្យនោះទេ។ ដោយសារតែនៅទីក្រុងភ្នំពេញ ខេត្តកណ្តាល ក្រុងព្រះសីហនុ សាលារៀនត្រូវបានបិទទៅហើយនោះដូច្នេះចំនួនសិស្សសាលាលោកគ្រូអ្នកគ្រូហើយបូកបន្ថែមដោយមន្ត្រីរាជការ គ្រប់ស្ថាប័នមិនទៅបំពេញការងារទៀត នឹងធ្វើឲ្យដងផ្លូវរបស់យើងមានការស្រឡះល្អ មិនកកកុញទៅដោយមនុស្ស ។ សម្តេចតេជោបានបញ្ជាក់ថា សម្រាប់ទីផ្សារ និងរោងចក្រ យើងមិនប្រកាសបិទនោះទេ ព្រោះមិនទាន់មានហានិភ័យទៅដល់កន្លែងនោះទេ។ ប៉ុន្តែសុំឲ្យមានការប្រុងប្រយ័ត្ន ជាមួយនឹងការការពារនៅតាមបណ្តារោងចក្រទាក់ទងនឹងការរាស់កំដៅ អាកុលលាងដៃ និងការតាមដានសុខភាពរបស់កម្មករ ជាប្រចាំ។ នៅតាមទីផ្សារ គឺត្រូវយកចិត្តទុកដាក់ពិនិត្យទៅលើស្ថានភាពដែលបាននិងកំពុងកើតហើយក៏ត្រូវពិនិត្យទៅលើអ្នកលក់និងអ្នកដែលត្រូវទិញផងដែរ ។

❋ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ តាមរយៈសារសំឡេង **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ចេញផែនការពន្លឿនការចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានប្រមាណ ១លានដូសក្នុងរយៈពេលមួយខែ។ ដើម្បីពន្លឿនការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា អភិបាលខេត្តទាំងអស់ ត្រូវទទួលរ៉ាប់រង់កន្លែងស្នាក់នៅរបស់ក្រុមគ្រូពេទ្យទៅពីទីក្រុងភ្នំពេញ ដែលស្ម័គ្រចិត្តទៅជួយ ឬចល័តពីកន្លែងមួយទៅកន្លែងមួយ ពីព្រោះ សព្វថ្ងៃសណ្ឋាគារ ផ្ទះសំណាក់ គឺមាននៅសល់ច្រើនដែលយើងអាច ពឹងពាក់ចំពោះម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ដើម្បីអាចផ្តល់ឲ្យគ្រូពេទ្យស្នាក់នៅបាន ដៀសវាងការយកថវិកាទៅជួលបន្ថែមក្នុងពេលដែលគ្រូពេទ្យស្ម័គ្រចិត្តទាំងនោះទៅជួយដល់ប្រជាជន គឺថ្នាក់ជាតិទទួលខុសត្រូវទៅលើថវិកាទាំងការធ្វើដំណើរ និងការហូបចុករបស់ក្រុមគ្រូពេទ្យ ។ ប៉ុន្តែការស្នាក់នៅជាសណ្ឋាគារ ឬផ្ទះសំណាក់ ត្រូវឲ្យអភិបាលខេត្តទទួលរ៉ាប់រង ទទួលខុសត្រូវ។ ដូច្នេះគណៈកម្មការចំពោះកិច្ច ឲ្យរៀបចំគម្រោងនៃការចំណាយតែទៅលើការធ្វើដំណើរ និងការហូបចុក ។ អភិបាលរាជធានី ខេត្ត ច្បាស់ជានឹងធ្វើបាននូវកិច្ចការងារនេះ ដោយមានការសហការល្អជាមួយម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់ នៅមូលដ្ឋាន ដើម្បីកាត់បន្ថយការចំណាយរបស់ថ្នាក់ជាតិដែលជាចំណូលរបស់សប្បុរសជនទុកចំណាយទៅលើប្រតិបត្តិការក្នុង ដំណើរការចាក់វ៉ាក់សាំងដែលត្រូវប្រើប្រាស់រយៈពេលនៃការចាក់វ៉ាក់សាំងមិនឲ្យអូសបន្លាយយូរ គឺត្រូវខិតខំចាក់ក្នុងកម្រិតមួយលាននាក់ក្នុងមួយខែ។ ប្រសិនបើវ៉ាក់សាំងមកច្រើនជាងនេះ យើងអាចចាក់លើសពីនេះ។ យើងបានទទួលព័ត៌មានថា តាមបណ្តាខេត្តបានរកទីកន្លែងចាក់បានសមគួរហើយដែរ ដែលមានជាង ៣០០កន្លែងនៅទូទាំងប្រទេសវាជាការល្អ ក៏ប៉ុន្តែលទ្ធភាពរបស់គ្រូពេទ្យជាបញ្ហា។ហេតុនេះគ្រូពេទ្យត្រូវតែរកនៅមូលដ្ឋានផងដែរទាំងគ្រូពេទ្យរដ្ឋ។ ប៉ុន្តែគ្រូពេទ្យរដ្ឋមិនត្រូវធ្វើឲ្យប៉ះពាល់ទៅដល់ដំណើរការនៃការព្យាបាលជំងឺសម្រាប់ជំងឺគ្រប់ប្រភេទដែលគ្រូពេទ្យកំពុងតែដំណើរការនោះទេ ។ យើងយកតែគ្រូពេទ្យដែលមិនជាប់ពាក់ព័ន្ធអាចជួយមកចាក់វ៉ាក់សាំងបានតែប៉ុណ្ណោះ។ ក្រៅពីនោះត្រូវចលនាពេទ្យគ្រូពេទ្យស្ម័គ្រតាមគ្លីនិកឯកជនក៏ដូចជាគ្រូពេទ្យដែលជាសេវាឯកជនយកមកធ្វើការហ្វឹកហ្វឺន ដើម្បីបង្កើនចំនួនគ្រូពេទ្យចាក់នៅតាមទីកន្លែងដែលបានរៀបចំរួចមកហើយបន្ថែមទៅដោយអន្តរាគមន៍នៃគ្រូពេទ្យស្ម័គ្រចិត្តដែលទៅពីថ្នាក់ជាតិ ដែលមានក្រុមគ្រូពេទ្យស្ម័គ្រចិត្តច្រើនក្រុមចុះទៅ ៕

នាយករដ្ឋមន្ត្រី កម្ពុជា ឡាវ និងវៀតណាម ជួបពិភាក្សាគ្នា ដើម្បីពង្រឹងចំណាក់ចំនងកិច្ចសហប្រតិបត្តិការប្រទេសជាំងបី



*សម្តេចតេជោ **ហ៊ុន សែន** ឯកឧត្តម **ថង់ឡុន ស៊ីសុលីត** និង ឯកឧត្តម **ឡៀ សួនហ្វុក** ជួបប្រជុំគ្នាតាមរយៈប្រព័ន្ធវីដេអូ ដោយបានពិភាក្សាទៅលើបញ្ហាសំខាន់ៗមួយចំនួន*

ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **ថង់ឡុន ស៊ីសុលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ឯកឧត្តម **ឡៀ សួនហ្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានជួបប្រជុំគ្នាតាមរយៈប្រព័ន្ធវីដេអូដោយបានពិភាក្សាទៅលើបញ្ហាសំខាន់ៗមួយចំនួនពាក់ព័ន្ធបញ្ហាកូវីដ១៩ ការបើកជើងហោះហើរឡើងវិញ និងការពង្រឹងទំនាក់ទំនងរវាងប្រទេសទាំង៣។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានឱ្យដឹងថាក្នុងជំនួបតាមប្រព័ន្ធវីដេអូនេះឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ និងវៀតណាម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគំនិតផ្តួចផ្តើមដ៏សំខាន់របស់សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ឱ្យមានជំនួបតាមប្រព័ន្ធវីដេអូ ដែលជាការរួមចំណែកពង្រឹង និងពង្រីកបន្ថែមទៀត នូវមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កានៃប្រទេសទាំងបី។ ក្នុងជំនួបនេះ នាយករដ្ឋមន្ត្រីទាំងបី បានជម្រាបជូននូវសភាពការណ៍វិវត្តន៍ថ្មីៗនៅក្នុងប្រទេសរបស់ខ្លួនរួមទាំងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩។ **សម្តេចតេជោហ៊ុនសែន**បានសម្តែងការអបអរសាទរចំពោះសមភាគីវៀតណាម និងឡាវ ចំពោះជោគជ័យនៃមហាសន្និបាតបក្សកម្មុយនីស្តវៀតណាមលើកទី១៣ និងមហាសន្និបាតបក្សប្រជាជនបដិវត្តន៍ឡាវលើកទី១១ ។ នាយករដ្ឋមន្ត្រីទាំងបី បានឯកភាពគ្នាពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩។ នាយករដ្ឋមន្ត្រីទាំងបី ក៏បានឯកភាពគ្នាក្នុងការផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ទៅវិញទៅមកដោយមិនគិតថ្លៃដល់មន្ត្រីការទូត និងសិស្សនិស្សិតកម្ពុជា ឡាវ និងវៀតណាម ដែលកំពុងស្នាក់នៅក្នុងប្រទេសនីមួយៗ។ នាយករដ្ឋមន្ត្រីទាំងបី បានសម្តែងនូវការពេញចិត្តរួមគ្នាចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ដែលកំពុងមានការរីកចម្រើនលើគ្រប់វិស័យរវាងប្រទេសទាំងបី ទោះបីស្ថិតក្នុងកាលៈទេសៈនៃភាពប្រឈមខ្លាំងបណ្តាលពីការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ។ នាយករដ្ឋមន្ត្រីទាំងបីក៏បានកត់សម្គាល់ដោយក្តីរីករាយនូវការកើនឡើងនៃទំហំពាណិជ្ជកម្មរវាងកម្ពុជា-ឡាវនិងកម្ពុជា-វៀតណាម។ ថ្នាក់ដឹកនាំទាំងបី បានឯកភាពពង្រឹងបន្ថែមកិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ សន្តិសុខ ការពារជាតិ ការគ្រប់គ្រងព្រំដែន ពាណិជ្ជកម្ម និងវិនិយោគ ការតភ្ជាប់ ថាមពល និងអប់រំ ។ នាយករដ្ឋមន្ត្រីទាំងបី ក៏បានឯកភាពបន្តរក្សា និងអនុវត្តន៍យ៉ាងមានប្រសិទ្ធភាពនូវយន្តការនៃកិច្ចសហប្រតិបត្តិការដែលមានស្រាប់, ជំរុញកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែន, អនុវត្តន៍ឱ្យមានប្រសិទ្ធភាពនូវរាល់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងព្រំដែន, សហការបន្ថែមក្នុងការការពារសន្តិសុខតាមបណ្តោយព្រំដែនរួម, សម្របសម្រួលសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងការឆ្លងកាត់របស់ប្រជាជន និងទំនិញនៅតាមបណ្តាប៉ុស្តិ៍ត្រួតពិនិត្យព្រំដែន។នៅក្នុងវិស័យការតភ្ជាប់នាយករដ្ឋមន្ត្រីទាំងបី បានឯកភាពពិចារណាអំពីការដំណើរការឡើងវិញនូវការហោះហើរអន្តរជាតិរវាងកម្ពុជា ឡាវ និងវៀតណាម ដើម្បីជំរុញពាណិជ្ជកម្ម និងការវិនិយោគក៏ដូចជាការផ្លាស់ប្តូររវាងប្រជាជននៃប្រទេសទាំងបី។

នៅក្នុងកិច្ចសហប្រតិបត្តិការក្របខណ្ឌអនុតំបន់ ប្រមុខដឹកនាំនៃប្រទេសទាំងបី បានឯកភាពពន្លឿនការអនុវត្តផែនការការតភ្ជាប់សេដ្ឋកិច្ច CLV ដល់ឆ្នាំ២០៣០ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការក្នុងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ ដើម្បីស្ថាបនាផ្លូវល្បឿនលឿនហាណូយ-វៀងចន្ទន៍ ផ្លូវរថភ្លើងវៀងចន្ទន៍-វ៉ុងអាន និងផ្លូវរថភ្លើងភ្នំពេញ-ហូជីមិញ។ ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម និងឡាវ បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការគាំទ្រយ៉ាងពេញទំហឹងចំពោះកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល អនុតំបន់មេគង្គលើកទី៧ នៅក្នុងខែមីនា ឆ្នាំ២០២១ កិច្ចប្រជុំកំពូល ASEM លើកទី១៣ នៅចុងឆ្នាំ២០២១ និងប្រធានអាស៊ានក្នុងឆ្នាំ២០២២។ ទន្ទឹមនេះនាយករដ្ឋមន្ត្រីទាំងបី បានឯកភាពចាត់តាំងឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្តពាក់ព័ន្ធទាំងអស់អនុវត្តន៍នូវការព្រមព្រៀងគ្នា ដែលបានសម្រេចនៅក្នុងជំនួបតាមប្រព័ន្ធវីដេអូនេះ ក៏ដូចជាការបង្កើនមិត្តភាព និងកិច្ចសហប្រតិបត្តិការពហុវិស័យរវាងបណ្តាប្រទេសទាំងបី កម្ពុជា-ឡាវ និងវៀតណាម ។ ថ្នាក់ដឹកនាំទាំងបីក៏បានផ្លាស់ប្តូរទស្សនៈគ្នា លើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ និងក្តីបារម្ភរួមផងដែរ៕

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានប្រកាសជាក់ឲ្យប្រើប្រាស់ជាផ្លូវការ

សម្តេចកិត្តិ ហេង សំរិន អញ្ជើញជាអធិបតីភាពក្នុងសម័យប្រជុំរដ្ឋសភាវិសាមញ្ញនីតិកាលទី ៦

នៅព្រឹកថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២១ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា បានអញ្ជើញជាអធិបតីភាពក្នុងសម័យប្រជុំរដ្ឋសភាវិសាមញ្ញនីតិកាលទី ៦ ដោយមានសមាជិក សមាជិកា រដ្ឋសភាចូលរួមចំនួន ៨៣ រូប ដើម្បីពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត។

អង្គប្រជុំរដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់នេះដែលមាន ៦ជំពូក និង១៨មាត្រាដោយសម្លេងគាំទ្រ៨៣សម្លេងលើ៨៣សម្លេង ។ ច្បាប់នេះបានក្លាយជាយន្តការមួយដ៏សំខាន់ក្នុងការកំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្ត ដើម្បីប្រយុទ្ធទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវដែលប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតក្នុងពេលបច្ចុប្បន្ន និងពេលអនាគត សំដៅការពារអាយុជីវិតប្រជាពលរដ្ឋ លើកកម្ពស់សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។ រដ្ឋសភាបានថ្លែងកោតសរសើរយ៉ាងក្រៃលែងចំពោះរាជរដ្ឋាភិបាល ដែលបានខិតខំដាក់ចេញវិធានការនានាក្នុងពេលកន្លងមក ដោយបានទប់ស្កាត់ចំពោះការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ធានាបាននូវកិច្ចការពារសុខុមាលភាពប្រជាពលរដ្ឋ បញ្ហាសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។ សេចក្តីព្រាងច្បាប់ថ្មីដែលកើតចេញជារូបរាងនេះ ជាសក្ខីភាពកាន់តែច្បាស់បង្ហាញពីកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលចំពោះអាយុជីវិត និងសុខុមាលភាពប្រជាពលរដ្ឋ។

មាត្រា ៧ នៃច្បាប់នេះ បានចែងថា ៖ «អំពើគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែង ធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលពិន័យអន្តរការណ៍តាមការកំណត់ នៅក្នុងអនុក្រឹត្យ ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល កាលបើអំពើខាងលើនេះ បានបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ» ។ មាត្រា ៨ បានចែងថា ៖ «អំពើគេចវេះពីការតម្រូវឲ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល ដែលកំណត់ដោយក្រសួងសុខាភិបាល ឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ទៅ ២០.០០០.០០០ រៀល ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំទៅ១០ឆ្នាំកាលបើអំពើខាងលើនេះបានបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ »។ មាត្រា ៩ ចែងថា ៖ «អំពើចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ឆ្នាំ ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ២០ ឆ្នាំ កាលបើអំពើខាងលើនេះត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុម ឬអង្គការចាត់តាំង» ។ មាត្រា ១០ ចែងថា ៖ «ដោយមិនគិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី ១.០០០.០០០រៀលទៅ ៥.០០០.០០០រៀល ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល កាលបើអំពើខាងលើនេះ បណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ដល់អ្នកដទៃ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០រៀលទៅ២០.០០០.០០០រៀល កាលបើអំពើខាងលើនេះបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ»។ មាត្រា ១១ ចែងថា ៖ «អំពើពារាំង ឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញ ស្របតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ៦ ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០រៀលទៅ ១០.០០០.០០០រៀល ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់ពី៥.០០០.០០០រៀលទៅ២០.០០០.០០០រៀល កាលបើអំពើខាងលើនេះបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

ច្បាប់នេះ ត្រូវបានសម័យប្រជុំព្រឹទ្ធសភា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភាពិនិត្យនិងឲ្យយោបល់នៅថ្ងៃទី១១ ខែមីនា ហើយត្រូវបាន **សម្តេចវិបុលសេនាកិត្តិ សាយ ឈុំ** ប្រមុខរដ្ឋស្តីទីចុះហត្ថលេខានៅថ្ងៃទី១១ ខែមីនា ដាក់ឲ្យប្រើប្រាស់ជាបន្ទាន់ ៕

សម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និង ប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** អញ្ជើញជាអធិបតីដ៏ខ្ពស់ខ្ពង់បើកសម័យប្រជុំវិសាមញ្ញ ព្រឹទ្ធសភា នីតិកាលទី៤*

នៅថ្ងៃព្រហស្បតិ៍ ទី១១ ខែមីនា ឆ្នាំ២០២១ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** ប្រធានស្តីទីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពស់ខ្ពង់បើកសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៣៩រូប។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដើម្បីកំណត់អំពីគោលបំណង វិសាលភាព វិធានការ ទោសប្បញ្ញត្តិ និងសមត្ថកិច្ច ដែលត្រូវអនុវត្តសំដៅការពារអាយុជីវិតប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃជំងឺឆ្លងនេះ ចំពោះវិស័យសង្គម-សេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះក៏បានបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការទទួលខុសត្រូវចំពោះភាពរស់រានមានជីវិតរបស់ប្រជាពលរដ្ឋ និងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងប្រឈមនឹងការគំរាមកំហែងពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

នៅក្នុងសម័យប្រជុំនោះ មានតំណាងរាជរដ្ឋាភិបាលពីររូបបានអញ្ជើញចូលរួមដើម្បីការពារសេចក្តីព្រាងច្បាប់នេះ ដែលរួមមាន ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ឯកឧត្តម **កើត រិទ្ធ** បានថ្លែងថា ច្បាប់នេះបានកសាងឡើងក្រោយពេលកម្ពុជា បានជួបប្រទះនឹងជំងឺឆ្លងកូវីដ១៩ ដែលជាជំងឺមួយមានសភាពស្រួចស្រាវធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ សេដ្ឋកិច្ច-សង្គម និងបង្កឱ្យបាត់បង់អាយុជីវិតពលរដ្ឋ, ដើម្បីទប់ស្កាត់ និងកាត់ផ្តាច់ការចម្លងការរីករាលដាលនៃជំងឺនៅក្នុងសហគមន៍កម្ពុជា ជាពិសេសគឺការពារអាយុជីវិតប្រជាពលរដ្ឋ និងសុខភាពសាធារណៈ។ ឯកឧត្តមថ្លែងថា ច្បាប់នេះធ្វើឡើងក្នុងគោលបំណងសំខាន់តែមួយគត់ គឺដើម្បីការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ ការពារសុខភាពសាធារណៈប្រជាជន។ ចំពោះទោសបញ្ញត្តិវិញ បង្កើតឡើងដើម្បីដាក់ទោសចំពោះជនខិលខូច និងជនទុច្ចរិត ដែលចង់បង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជន និងសុខភាពសាធារណៈតែប៉ុណ្ណោះ។ សម្រាប់ប្រជាពលរដ្ឋដែលគោរពតាមវិធានការត្រឹមត្រូវរបស់រាជរដ្ឋាភិបាល របស់ក្រសួងសុខាភិបាលធានាបានមិនឱ្យមានការឆ្លងរាលដាល ធ្វើឱ្យសហគមន៍របស់យើងអាចវិលត្រឡប់ទៅរកស្ថានភាពប្រក្រតីឡើងវិញ ច្បាប់នេះអត់យកទៅអនុវត្តន៍ចំពោះពួកគាត់ទេ។ទោសបញ្ញត្តិនេះគេអនុវត្តន៍តែចំពោះជនខិលខូចចំពោះជនទុច្ចរិត ដែលមានចេតនាធ្វើឱ្យសង្គមកម្ពុជាមានភាពវឹកវរតែប៉ុណ្ណោះ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន៣៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាល មាន ០៦ជំពូក និង១៨ មាត្រាត្រូវបានរដ្ឋសភាកម្ពុជាអនុម័តយល់ព្រមជាលើកដំបូងចំនួន ៨៣សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជានាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញជាអធិបតីក្នុងពិធីវាយគង ជួង រគាំង ទូងស្គរ នៅវត្តលង្កាព្រះកុសុមារាមដែលស្ថិតនៅសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ក្រោមព្រះវត្តមាន សម្តេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទថុល្ល ព្រះចៅអធិការវត្ត ។

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឡេង ឆន** សមាជិកគណៈអចិន្ត្រៃយ៍ នៃ គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជាអនុប្រធានទី២ព្រឹទ្ធសភារួមដំណើរដោយឯកឧត្តម **ម៉ម ប៊ុនឆាង** ប្រធានគណៈកម្មការទី១០ និងសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានអញ្ជើញនាំយកអំណោយដែលរួមមានមី ចំនួន២.០០០កេស និងទឹកសុទ្ធ ចំនួន២.០០០កេស ជូនដល់រដ្ឋបាលខេត្តកណ្តាល សម្រាប់ចែកជូនដល់បងប្អូនប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័កតាមបណ្តាស្រុក-ក្រុងទូទាំងខេត្តកណ្តាល។

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល បានអញ្ជើញជួបសំណេះសំណាលត្រួតពិនិត្យការងារ និងប្រគល់អំណោយជូនដល់រដ្ឋបាលខេត្តកណ្តាល សម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ នៅសាលាខេត្តកណ្តាល។

ថ្ងៃទី០១ ខែមិនា ឆ្នាំ២០២១ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អគ្គទេសាភិបាលធនាគារជាតិកម្ពុជា និងលោកជំទាវ បានអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាកសាង អគារពុទ្ធិកវិទ្យាល័យមួយខ្នង កម្ពស់៤ជាន់ ស្ថិតនៅវត្តរាជបូណ៌ ក្រុងសៀមរាប ខេត្តសៀមរាប។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បាន អញ្ជើញចូលរួមសន្និសីទ អភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ឆ្នាំ២០២១ ស្តីពី នវានុវត្តន៍តាមរយៈកិច្ចសហ-ប្រតិបត្តិការ ការរៀបចំផែនការស្តារឡើងវិញប្រកបដោយបរិយាប័ន្ន បន្ទាប់ពី Covid-19 បញ្ចប់ តាមរយៈ ប្រព័ន្ធវីដេអូ Conference ។

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ហ៊ុន ណេង** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារ សាធារណៈនៃ រដ្ឋសភា និងលោកជំទាវ **លាង ឡូចឆេង** បានឧបត្ថម្ភអំណោយជាថវិកា និងស្បៀងអាហារ ដល់បងប្អូនកម្មកររបស់ ក្រុមហ៊ុន ស៊ិនទ្រី ចំនួន ៣៩នាក់ ដែលកំពុងប្រមូលសម្រាម នៅក្នុងក្រុងកំពង់ចាម ខេត្តកំពង់ចាម។

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ថោង ខុន** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងារចុះជួយស្រុកបារាយណ៍ និងស្រុកតាំងគោក ខេត្តកំពង់ធំ បានអញ្ជើញដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានកំពុងកសាងផ្លូវលំមួយខ្សែប្រវែង១២ គីឡូម៉ែត្រ ជូនប្រជាពលរដ្ឋនៅភូមិ គោកត្របែក ឃុំស្រឡៅ ស្រុកតាំងគោក។ ឯកឧត្តមថ្លែងថា តាមរយៈ សមិទ្ធផលផ្លូវនេះ នឹងធ្វើឱ្យភូមិគោកត្របែកលែងជាតំបន់ដាច់ស្រយាល។

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ខៀវ កាញ្ញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួង ព័ត៌មាន ដឹកនាំសហការីអញ្ជើញចូលរួមសន្និសីទ លើកទី១៥ នៃរដ្ឋមន្ត្រី អាស៊ាន ទទួលបន្ទុកផ្នែកព័ត៌មាន ក្រោមប្រធានបទ **«សហគមន៍ឌីជីថលមួយ ដែលអាចចូលរួមបានទាំងអស់គ្នា»** ដែលប្រទេសថៃធ្វើជាម្ចាស់ផ្ទះតាម ប្រព័ន្ធ វីដេអូ នៅទីស្តីការក្រសួង។

ដើម្បីចូលរួម អបអរសាទរទិវា នារីអន្តរជាតិ ៨ មីនា នៅរសៀល ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ព្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសា-ធារណៈរួមជាមួយ ក្រុមការងារ ស្រុក បាភ្នំ បាន ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខលោក យាយ លោកតា ចាស់ៗ សរុប ចំនួន៧០នាក់ មកពីឃុំធាយ ឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ព្រឹកថ្ងៃបន្ទាប់ នៃខែឆ្នាំដដែល ឯកឧត្តមប្រធានក្រុមការងារខេត្ត ក្រចេះក៏បានជួបសំណេះសំណាលជាមួយលោកយាយ លោកតាចាស់ៗចំនួន ៥៤នាក់ មកពីភូមិដង្ហិត ភូមិប្រឡាយទ្រៀក ភូមិក្រូច និង ភូមិ២៧សែនជ័យ នៃឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។ លោកយាយ លោកតាទាំងអស់នេះ កំពុងជួបការលំបាកក្នុងជីវភាព ម្យ៉ាងអាស្រ័យដោយ ត្រូវប្រឈមនឹងផលវិបាកនៃជំងឺកូវីដ-១៩ និងម្យ៉ាងទៀតត្រូវទទួលបន្ទុកចិញ្ចឹមបីបាច់ថែ រក្សាចៅតូចៗ ដែលឱពុកម្តាយពួកគេត្រូវធ្វើចំណាក ស្រុកទៅធ្វើការនៅទីឆ្ងាយ។ នៅក្នុងឱកាសនោះ ក្រុមការងារបានពាំនាំនូវអំណោយ ជាសំលៀកបំពាក់ និងថវិកាមួយចំនួនជូនពួកគាត់ផងដែរ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ស្សោច សាវ៉ាត** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រៃវែង អមដំណើរដោយឯកឧត្តមសមាជិកអចិន្ត្រៃយ៍គណបក្សខេត្ត ប្រធាន អនុប្រធានគណបក្សស្រុកពាមរ៉ាង និងសហការី បានអញ្ជើញចុះសួរសុខទុក្ខសិស្សានុសិស្សចំនួន ២៨នាក់ ដែលកំពុងធ្វើចត្តាឡីស័ក នៅវិទ្យាល័យ ហ៊ុន សែន កំពង់ពពិល ស្រុកពាមរ៉ាង រួមទាំងកម្លាំងការពារ និងពេទ្យ។ ជាមួយនោះឯកឧត្តមបានចែកជូននូវអំណោយជាសម្ភារៈ ថវិការួមមាន មីដែលម៉ាស់ និងថវិកាក្នុងម្នាក់ៗទទួលបាន៦០,000រ ។

ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ជាម ប៉ែរ** អ្នកតំណាងរាស្ត្រខេត្តព្រៃវែង បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារត្រៀមទទួលបងប្អូនចំណាកស្រុកវិលត្រឡប់មកចូលឆ្នាំប្រពៃណីខ្មែរ ស្របនឹងការរីករាលដាលជំងឺឆ្លង Covid19 សហគមន៍២០ កុម្ភៈ នៅស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ ឯកឧត្តមថ្លែងថាវិធានការសុខាភិបាល ពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតពីគ្នាជាវិធានការមុតស្រួចក្នុងការចូលរួមទប់ស្កាត់ជំងឺឆ្លងកាចសាហាវ Covid 19 ។ ស្រុកស៊ីធរកណ្តាលបានត្រៀមទីតាំងសម្រាប់ធ្វើចត្តាឡីស័ក្តគ្រប់ឃុំទាំង១១ សម្រាប់ទទួលបងប្អូនចំណាកស្រុកមកពីប្រទេសថៃ និងតំបន់ផ្សេងៗដែលតម្រូវឲ្យធ្វើចត្តាឡីស័ក។ ឯកឧត្តម បានឧបត្ថម្ភបន្ថែមអាល់កុល ជែល ទឹកបរិសុទ្ធ និងថវិកាមួយចំនួនផងដែរ។

ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ជា សុមេធី** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តព្រៃវែង បានអញ្ជើញជួបសួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ ដើម្បីជួយសម្រាលទុក្ខលំបាករបស់មណ្ឌលកុមារកំព្រាខេត្ត និងអង្គការសហព័ន្ធនារីពិការក្នុងកំឡុងពេលការរីករាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលមានចំនួនសរុប ១៦០នាក់នៅភូមិលេខ៦ និងភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង។

ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមខេត្តត្បូងឃ្មុំ បាននាំយកអំណោយសាខាកាកបាទក្រហមខេត្ត ចែកជូនពលរដ្ឋ ដែលរងផលប៉ះពាល់ ដោយការរីករាលដាលជំងឺកូវីដ-១៩ ចំនួន២១០គ្រួសារ នៅចំនួន៤ទីតាំងផ្សេងគ្នា ក្នុងភូមិស្រែប្រាំង ឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។ ឯកឧត្តមបានណែនាំឱ្យបងប្អូនទាំងអស់ ត្រូវរក្សាអនាម័យឲ្យបានជាប់ជាប្រចាំ រក្សាគម្លាតសង្គម ពាក់ម៉ាស់ លាងដៃនឹងអាល់កុលឬជែល ពិសេសអនុវត្តន៍តាមវិធានការ **"៣ការពារ ៣កុំ"** ឲ្យបានជាប់ជាប្រចាំ។

ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ លោកជំទាវ **បាន ស្រីមុំ** សមាជិកាគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយទៅឧបត្ថម្ភដល់បងប្អូនអតីតយុទ្ធជន ចំនួន៨០គ្រួសារ មកពីឃុំទាំង ០៤ ក្នុងស្រុកសាលាក្រៅ ខេត្តប៉ៃលិន។ លោកជំទាវថ្លែងថា ថ្នាក់ដឹកនាំខេត្ត ក៏ដូចជាសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត យកចិត្តទុកដាក់ជួយសាងសង់ផ្ទះសម្បែង ផ្តល់ដីបង្កបង្កើនផលឧបត្ថម្ភថវិកាស្បៀងអាហារផ្សេងៗជូនពួកគាត់ដែលមានជីវភាពខ្វះខាត ដើម្បីឱ្យក្រុមគ្រួសារអតីតយុទ្ធជនយើង មានលទ្ធភាព បន្តការងារប្រកបមុខរបរចិញ្ចឹមជីវិត តាមលទ្ធភាពរៀងៗខ្លួន។

សកម្មភាពសមាជិកវុឌ្ឍសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២១ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាប្រធានគណៈកម្មការខេត្តប្រយុទ្ធប្រឆាំងនឹងជងឺកូវីដ១៩ បានដឹកនាំកិច្ចប្រជុំត្រៀមទីតាំង បន្ទប់ព្យាបាល និងបន្ទប់ដាក់ដាច់ដោយឡែកសម្រាប់អ្នកឆ្លងជំងឺកូវីដ១៩ ក្នុងភូមិសាស្ត្រខេត្តកំពត។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពី លោកជំទាវ អភិបាលរងខេត្ត ប្រធានមន្ទីរសុខាភិបាល ប្រធានមន្ទីរពេទ្យបង្អែកទាំង៥ និងមន្ត្រីជំនាញ នៅសាលប្រជុំសាលា ខេត្តកំពត។

ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ស្វាយ សំអ៊ាង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលខេត្តមណ្ឌលគិរី អមដំណើរដោយអភិបាលរងខេត្ត ស្នងការនគរបាលខេត្តរួមទាំងថ្នាក់ដឹកនាំមន្ទីរជំនាញ បានអញ្ជើញចុះពិនិត្យមើលការបើកយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ- ១៩ ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លារបស់សាធារណរដ្ឋប្រជាមានិតចិនហើយវ៉ាក់សាំងដែលត្រូវចាក់នេះមាន ឈ្មោះថា **ស៊ីណូហ្វាម** ដែលប្រព្រឹត្តទៅនៅមន្ទីរពេទ្យបង្អែកខេត្ត ស្ថិតនៅក្រុងសែនមនោរម្យ។

ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ម៉ុម សារឿន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង បានអញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃការស្ថាបនាផ្លូវក្រាលក្រួសក្រហមតាមបណ្តោយទន្លេមេគង្គបន្ត (ពីអូរតាខេង ដល់អូរភ្នុល) ប្រវែង ៧.៤០០ម៉ែត្រ ទទឹង៧ម៉ែត្រ លូមូលភ្លោះចំនួន ៣កន្លែង និងស្ពានដែកបាឡែក្បាលបេតុងចំនួន ២កន្លែង ដែលស្ពានទី១ មានប្រវែង២៤ម៉ែត្រ ស្ពានទី២ មានប្រវែង ២៧ម៉ែត្រ ព្រមទាំងអគារប៉ុស្តិ៍សុខភាព និងការតភ្ជាប់បណ្តាញអគ្គិសនី ស្ថិតក្នុងឃុំកាំងចាម ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង តភ្ជាប់ដល់ឃុំសៀមបូក ស្រុកសៀមបូក។

ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ម៉ែន វិបុល** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង អមដំណើរដោយអភិបាលរងខេត្ត ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងអភិបាលស្រុកស្វាយជ្រំ បានអញ្ជើញចុះពិនិត្យការរៀបចំ និងពង្រឹងការងារសុវត្ថិភាព ការងារសន្តិសុខ នៅខាងក្នុង និងខាងក្រៅមន្ទីរពេទ្យបង្អែកស្វាយជ្រំ ដែលជាមន្ទីរពេទ្យព្យាបាលជំងឺកូវីដ១៩។ ឯកឧត្តមអភិបាលខេត្ត បានណែនាំរដ្ឋបាលស្រុក ត្រូវសហការជាមួយមន្ទីរសុខាភិបាលដោយយកទីតាំងអគារអនុសាខាកាកបាទក្រហមកម្ពុជាស្រុក ឬការិយាល័យភូមិបាលស្រុក សម្រាប់ធ្វើជាទីតាំងចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនមន្ត្រីរាជការរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ អនុប្រធានភូមិ ជំនួយការភូមិ និងមន្ត្រីកិច្ចសន្យា។

ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ អមដំណើរដោយ លោកវេជ្ជបណ្ឌិត **រឿន សុធី** អនុប្រធានមន្ទីរសុខាភិបាលខេត្ត បានអញ្ជើញចុះពិនិត្យ និងណែនាំវិធានការបន្ថែមដល់ក្រុមការងារចម្រុះប្រចាំការនៅមណ្ឌលចត្តាឡីស័កស្រុកស្វាយចេក ស្រុកថ្មពួក ស្រុកភ្នំស្រុក និងមណ្ឌលធ្វើចត្តាឡីស័ក ស្រុកព្រះនេត្រព្រះ ដើម្បីពង្រឹងការគ្រប់គ្រង សម្របសម្រួលបងប្អូនធ្វើចត្តាឡីស័កឲ្យបាន ហ្មត់ចត់តាមវិធានការសុខាភិបាល។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ក្រោមការចង្អុលបង្ហាញពីឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាលឯកឧត្តម **ហួត ហាក់** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍ យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានលេខាធិការដ្ឋាន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំក្រុមការងារចុះសម្របសម្រួលផ្ទាល់ និងសហការណ៍ជាមួយបងៗ ទំពាអាវសរជួរមុខ ដើម្បីផ្តល់វ៉ាក់សាំងAstraZeneca ការពារជំងឺកូវីដ-១៩ ជូនថ្នាក់ដឹកនាំយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងក្រុមគ្រួសាររបស់សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ និងចូលរួមជួយបំផុសចលនាវិធានការ ៣ការពារ ៣កុំ ជាប់ជានិច្ច សរុបចំនួន ២០៩នាក់ មន្ទីរពេទ្យព្រះអង្គឌួង។

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ជ្រុន ថេរ៉ាឌ័ត** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍ យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានជនបង្គោលយុវជនថ្នាក់ កណ្តាលទទួលបន្ទុកស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយមានការណែនាំដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាលនិងជាអនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ចាមបានដឹកនាំក្រុមការងារយុវជនស្រុកព្រៃឈរ ចុះធ្វើសកម្មភាពផ្សព្វផ្សាយ អំពីការការពារ និងទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដល់អាជីវករ និងប្រជាពលរដ្ឋនៅផ្សារព្រៃទទឹង និងផ្សារគរ ដោយអនុវត្តវិធានការ ៣ ការពារ និង ៣ កុំ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ហាក់ សុខមករា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ និងក្រុមការងារបានរៀបចំពិធីសំណេះសំណាលជាមួយក្រុមកីឡាបាល់ទាត់យុវជនគណបក្សខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាព ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ ដែលមានការចូលរួមពីលោកប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន លោក លោកស្រីប្រធាន គណៈកម្មការសាខាបក្ស មន្ទីរ អង្គភាពជុំវិញខេត្ត ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកខ.២៦.១ ខ២៦.២ និង ខ.២៧ មន្ត្រីដឹកនាំ និងកីឡាករផងដែរ នៅទីស្នាក់ការគណបក្សប្រជាជនខេត្តត្បូងឃ្មុំ។

ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **អ៊ូច តា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តតាកែវ បានបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមអចិន្ត្រៃយ៍ និងផែនចំណុះក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តតាកែវ និងផ្តល់នូវកុំព្យូទ័រយួរដៃដល់ក្រុមការងារយុវជនគណបក្សក្រុងស្រុក ចំនួន១០គ្រឿងផងដែរ ដើម្បីបំពេញកិច្ចការសំខាន់ៗចំពោះមុខ នៅទីស្នាក់គណបក្សប្រជាជនកម្ពុជាខេត្តតាកែវ ។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ហាក់ សុខមករា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ បានចុះជួបសំណេះសំណាលជាមួយសកម្មជនយុវជនទាំង ២០ភូមិ និងក្រុមការងារយុវជនឃុំស្រឡប់ ដើម្បីពង្រឹងការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពយុវជនគណបក្សឃុំ-ភូមិ និងដាក់ផែនការឆ្ពោះទៅកាន់ការចុះឈ្មោះបោះឆ្នោតខែកញ្ញា ឆ្នាំ២០២១ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ខាងមុខនេះ នៅទីស្នាក់ការគណបក្សឃុំស្រឡប់ ក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ លោក **ស្រី សុភ័ក្ត្រ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពង់ចាម បានចុះជួបសំណេះសំណាលជាមួយក្រុមយុវជនសកម្មផ្នែកបណ្តាញសង្គម ដើម្បីពង្រឹងស្មារតីដល់យុវជនសកម្មភាពទាំងអស់ ពិសេសគឺឱ្យពួកគាត់មានមោទនភាពដែលបានចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា សរុបអ្នកចូលរួមចំនួន ៧០នាក់ នៅស្រុកកោះសូទិន ខេត្តកំពង់ចាម។

ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ឯកឧត្តម **រាជ ង៉ា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សក្រសួងពាណិជ្ជកម្ម និងឯកឧត្តម **អ៊ុក ប្រថា** ប្រធានកិត្តិយសក្រុមការងារយុវជនគណបក្សក្រសួងពាណិជ្ជកម្ម បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារបន្តឆ្នាំ២០២១ របស់ក្រុមការងារយុវជនគណបក្សក្រសួងពាណិជ្ជកម្ម។

ថ្ងៃទី៣ ខែមករា ឆ្នាំ២០២១ លោក **សាយ ម៉េងគីម** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តមណ្ឌលគីរី បានដឹកនាំកិច្ចប្រជុំក្រុមអចិន្ត្រៃយ៍នៃយុវជនគណបក្សខេត្ត ពិនិត្យ ពិភាក្សា លិខិតបទដ្ឋាននានា និងផ្សព្វផ្សាយសេចក្តីសម្រេចផ្សេងៗរបស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដោយមានការចូលរួមពីលោក លោកស្រីអនុប្រធាន សមាជិក សមាជិកាក្រុមអចិន្ត្រៃយ៍យុវជនគណបក្សខេត្ត នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តមណ្ឌលគីរី។

ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២១ ឯកឧត្តម **ឌី វ៉ាង** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារយុវជនគណបក្សខេត្ត ចុះជួយលើកផ្ទះជូនដល់គ្រួសារងគ្រោះដោយភ្លើងឆេះផ្ទះនៅក្នុងភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ និងនាំយកអំណោយជូនដល់គ្រួសារជួបការលំបាក ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ថ្ងៃទី៩ ខែមីនា ឆ្នាំ ២០២១ លោក **អ៊ុក គីមសាន** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តព្រះវិហារ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការកែសម្រួល សមាសភាពក្រុមការងារយុវជនគណបក្សខេត្ត ដែលមានការកែសម្រួលចេញ និងបញ្ចូលសមាសភាពថ្មីបន្ថែម ដើម្បីឲ្យសមស្របការងារចាំបាច់នាពេលបច្ចុប្បន្ន នៅទីស្នាក់ការគណបក្សប្រជាជនខេត្តព្រះវិហារ។

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ឯកឧត្តម **ហោ ស្ថី** សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាលបានដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីនិងក្រុមជំនួយការប្រចាំការ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ពិនិត្យពីវឌ្ឍនភាពការងារប្រចាំខែ និងទិសដៅបន្ត ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ និងបានរំលឹកវិធានសុខាភិបាល ៣ការពារ និង៣កុំ ដល់ក្រុមជំនួយការឲ្យបន្តអនុវត្តឲ្យជាប់ជាប្រចាំនៅការិយាល័យយុវជនគណបក្សថ្នាក់កណ្តាល (រឹមនៃ ៧មករា)។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

❋ ក្នុងខែមករា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងអាមេរិក សម្រេចបានចំនួន ៦១៤,៥ លានដុល្លារកើនឡើង ៤,៨៩% ធៀបនឹងខែមករាឆ្នាំ២០២០ ដែលមានចំនួន៥៨៥,៨ លានដុល្លារ។ ក្នុងនោះ ការនាំចេញពីកម្ពុជាទៅអាមេរិកមានតម្លៃ ៥៨០,៦លានដុល្លារកើនឡើង ៣,៦៩% ពីចំនួន ៥៥៩,៩លានដុល្លារ ។ រីឯការនាំចូលពីអាមេរិកមកកម្ពុជាមានតម្លៃ៣៣,៩លានដុល្លារ កើនឡើងពីចំនួន២៥,៩លានដុល្លារ ឬស្មើនឹង៣០,៨៨%។

• រយៈពេល ២ខែដើមឆ្នាំ

❋ កំពង់ផែស្វយ័តភ្នំពេញរកចំណូលបានចំនួន៤.៩៧៧.៤៨១ ដុល្លារ មានការថយចុះ០.៦%បើធៀបរយៈពេលដូចគ្នាឆ្នាំ២០២០ មានចំនួន៥.៣០៨.២៨៤ដុល្លារ។ប្រភពចំណូលរបស់កំពង់ផែស្វយ័តភ្នំពេញ ដែលទទួលបានរួមមាន៖ ទី១- ចំណូលបានប្រតិបត្តិការផែ មានចំនួន ៤.០០០.៦១០ដុល្លារ ទី២- ចំណូលបានពីអាជ្ញាធរផែ មានចំនួន៥៥៣.៤០៥ដុល្លារ ទី៣-ចំណូលបានពីសេវាកម្មផ្សេងៗ មានចំនួន ៥៩.២២០ដុល្លារ និងទី៤- ចំណូលផ្សេងៗ មានចំនួន ៣៦៤.២៤៦ដុល្លារ។ លទ្ធផលការងារអាជីវកម្ម សេវាកម្ម អនុវត្តសម្រាប់២ខែ ដើមឆ្នាំ២០២១ រួមមាន៖ ទី១- ទំនិញ-ប្រេងឥន្ធនៈ មានចំនួន៧០០.១០២តោន កើនឡើង៥,៤៨% បើប្រៀបធៀបនឹងឆ្នាំ២០២០ ចំនួន៦៦៣.៧៤០តោន ទី២-នាវាផ្ទុកទំនិញ ឆ្លងកាត់ មានចំនួន៣៩៩ជើង ថយចុះ១២,១១%បើប្រៀបធៀបនឹងឆ្នាំ២០២០ ចំនួន៤៥៤ជើង និងទី៣- បរិមាណកុងតឺន័រ មានចំនួន៥២.៦៦៤ ធីអឹយូ កើនឡើង៥,៦២% បើប្រៀបធៀបនឹងឆ្នាំ២០២០ ចំនួន ៤៩.៨៦០ធីអឹយូ។

❋ កម្ពុជានាំចេញកៅស៊ូសរុបចំនួន ៨៣.៦២០ តោន កើន ១០,៣% ពី ចំនួន ៧៥.៨០៩ តោន ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២១ កម្ពុជាមានផ្ទៃដីដាំកៅស៊ូសរុប ៤០៤.១១៨ហិកតានិងផ្ទៃដីប្រមូលផល២៩២.៤៩៧ ហិកតា។ (តម្លៃកៅស៊ូបានកើនឡើងពីចន្លោះ១៤០០ដុល្លារដល់១ ៧០០ដុល្លារ ក្នុង១តោន)។

❋ កម្ពុជានាំចេញផ្លែស្វាយស្រស់ចំនួន ៤៣៦៨០តោន ។ ទីផ្សារស្វាយរបស់កម្ពុជារួមមាន៖ ចិន ថៃ វៀតណាម រុស្ស៊ី បារាំង និងកូរ៉េខាងត្បូង។

❋ ភ្ញៀវទេសចរទិញបណ្ណចូលទស្សនាវមណីយដ្ឋានអង្គរមានចំនួន ៤.១៩៤នាក់ ធ្លាក់ចុះ ៩៨,៧៧% ធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ រីឯចំណូលបានមកពីការលក់សំបុត្រចូលទស្សនាមានចំនួនសរុប ១៧២.៨២៣ដុល្លារ ធ្លាក់ចុះ៩៨,៩៣%។

❋ កម្ពុជានាំចេញដំឡូងមី ចំនួន៩៥៧.២០១,៥៦ តោន ក្នុងនោះដំឡូងមីស្រស់ ១៥៤.៧៥០តោន។

❋ កម្ពុជានាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ មានចំនួនសរុប ១.៥៩៩.៩២២ តោន កើនឡើង ៥៥% ទៅកាន់ទីផ្សារគោលដៅ ២៥ប្រទេស។ ក្នុងចំណោមផលិតផលកសិកម្មដែលបាននាំចេញរួមមាន៖ ដំឡូងមី ៨០២.៤៥១,៥៦តោន , ដំឡូងមី-

ស្រស់មានចំនួន១៥៤.៧៥០តោន។ស្រូវចំនួន២៨៧.៨៥០តោន ដោយមិនបានឆ្លងកាត់ច្រកភូកគាមអនាម័យមានចំនួន៥៥៩.០៣៣ តោន។ ស្វាយចន្ទី៧៩៤៧៣តោន, គ្រាប់ពោតក្រហម ៧៨៨៥៦ តោន, ផ្លែស្វាយស្រស់ ៤៣៦៨០ តោន, ម្ទេសស្រស់ ៣២៤១៧ តោន, ដូងប្រេង ១៧៦ តោន, កន្ទក់៦២៥០តោន និងផលិតផលកសិកម្មចំនួន៣៣មុខទៀតសរុប៣១៣៧១តោន ។

គិតចាប់ពីខែមករា មកត្រឹម ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២១ កម្ពុជាសម្រេចបានការនាំចេញ ស្រូវ ទៅកាន់ ប្រទេស វៀតណាម ចំនួន ១ ១៤៦ ៨៤៤ តោន ។ក្នុងនោះ ខេត្តស្វាយរៀងបាននាំចេញកសិផលមានជាអាទិ៍ ដូចជា៖ ស្រូវចម្រុះ ១១៧ ៨៨៣តោនដំឡូងមី ស្រស់ ចំនួន ២ ២៧១ តោន ផ្លែស្វាយ កែវ រមៀត ស្រស់ ៣៦ ១៥៩ តោន និង អំពៅស្ក ១៤៦ ០៤១ តោន ។ ដោយឡែក ខេត្តព្រៃវែង បាននាំស្រូវចេញសរុបចំនួន ៧០៧ ៤៣១ តោន និង ស្វាយកែវ រមៀត បាន ចំនួន ៨៩ ៣៤០ តោន ។

• ត្រីមាសទី១ ដើមឆ្នាំ២០២១

❋ គម្រោងវិនិយោគដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា មានសរុប ៤៩គម្រោង ក្នុងនោះ ៣៣គម្រោង ស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស និង ១៦គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេសមានទុនវិនិយោគសរុប ២.២០៧.៣៥០.១០០ដុល្លារ ដែលអាចបង្កើតការងារបានចំនួន២៩.៤៤៣កន្លែង។នៅក្នុងនោះការវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មមាន ៤គម្រោង មានទុនវិនិយោគ ៤៣.០៦៣.៣២០ដុល្លារ,វិស័យឧស្សាហកម្ម និងកម្មន្តសាលមាន ៤០គម្រោង មានទុនវិនិយោគ ៨១៦.០៨៨.៦៨៤ដុល្លារ , វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗមាន ៥គម្រោង មានទុនវិនិយោគ ១.៣៤៨.១៩៨.០៩៦ដុល្លារ ។ នៅក្នុងចំណោមអ្នកបណ្តាក់ទុន-វិនិយោគទាំងនោះ ប្រទេសចិនជាប់លំដាប់ដំបូងគេ គឺ ៧០,៧៥% និងបន្ទាប់មក គឺការវិនិយោទុនក្នុងស្រុកមាន ២១,៣២% ។

ដោយឡែក ក្នុងខែមីនា ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជាបានអនុម័តគម្រោងវិនិយោគ មានសរុប ១៥គម្រោង ក្នុងនោះ ៩គម្រោង ស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស និង ៦គម្រោង ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានទុនវិនិយោគសរុប ១.៣៩០.៨១៦.០៦៩ដុល្លារ ដែលអាចបង្កើតការងារបានចំនួន ៦.៦៨១កន្លែង ៕

កម្ពុជាអនុវត្តគោលនយោបាយការបរទេសរឹងមាំ ទន់ភ្លន់ បត់បែន និងការពារផលប្រយោជន៍គោលរបស់ជាតិ

❋ យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច គឺជាអាទិភាពសម្រាប់គោលនយោបាយការបរទេសកម្ពុជា

*ឯកឧត្តម **ប្រាក់ សុខុន** អញ្ជើញចូលរួមកិច្ចប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការបរទេសអាស៊ាន (IAMM) ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ*

ព្រះរាជាណាចក្រកម្ពុជា បានប្រកាន់ខ្ជាប់នយោបាយការបរទេសមួយដែលបម្រើ លើកស្ទួយ និងការពារផលប្រយោជន៍គោលរបស់ជាតិ, ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព រក្សាការពារឲ្យបានគង់មាំនូវសន្តិភាព សន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងឯកភាពសង្គម ស្របតាមពាក្យស្លោក **"កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ"**។ កម្ពុជាក៏បានជំរុញការអនុវត្តការទូតសេដ្ឋកិច្ច ដើម្បីបង្កលក្ខណៈអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការការពារ និងលើកកម្ពស់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋកម្ពុជាទាំងក្នុង និងក្រៅប្រទេស។

ក្នុងឆ្នាំ២០២០ កម្ពុជាបានបំពេញភារកិច្ចការទូតយ៉ាងសកម្ម ក្នុងប្រក្រតីកម្មថ្មីនៃជំងឺរាតត្បាតកូវីដ-១៩ ដោយផ្តោតលើការងារជាអាទិភាពមួយចំនួនមានដូចជា ការបង្ហាញទៅសហគមន៍អន្តរជាតិអំពីតួនាទីកាន់តែសកម្មឡើងរបស់កម្ពុជា ក្នុងការគាំទ្រលើកស្ទួយ និងពង្រឹងពហុភាគីនិយម និងប្រព័ន្ធអន្តរជាតិដែលផ្អែកលើវិធានច្បាប់។ កម្ពុជាបានរៀបចំកិច្ចប្រជុំឧត្តមមន្ត្រី ASEM ចំនួន០១លើក និងកិច្ចប្រជុំឧត្តមមន្ត្រីប្រទេសសម្របសម្រួល និងម្ចាស់ផ្ទះកិច្ចប្រជុំកំពូល ASEM ៨លើក ដែលឈានដល់ការចេញសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីការបរទេសស្តីពីជំងឺរាតត្បាតកូវីដ-១៩។ ការតស៊ូយ៉ាងស្វិតស្វាញក្នុងការស្រាយបំភ្លឺ និងវាយបកចំពោះការចោទប្រកាន់ បំផ្លើសព័ត៌មាន និងការមូលបង្កាច់ពាក់ព័ន្ធនឹងគោលការណ៍ជាសារវន្តនៃនយោបាយការបរទេសរបស់កម្ពុជា គឺអព្យាក្រឹតជាអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ រក្សាសន្តិភាព និងវឌ្ឍនភាពផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ ដែលសម្រេចបានយ៉ាងលំបាក។ ការជួយឧបត្ថម្ភគាំពារប្រជាពលរដ្ឋកម្ពុជាដែលជាប់គាំងនិងជួបប្រទះការលំបាកនៅក្រៅប្រទេសដោយសារវីរុសកូរ៉ូណាដាល នៃជំងឺកូវីដ-១៩ ក៏ដូចជាការជួយជនជាតិបរទេសដែលជាប់គាំងនៅកម្ពុជា ជាពិសេសការអនុញ្ញាត ឲ្យនាវាទេសចរណ៍ MS Westerdam ដែលមាននាវិក និងអ្នកដំណើរចំនួន ២២៥៧ នាក់ ចូលចតក្រោយពីប្រទេសមួយចំនួនបដិសេធដោយហេតុផលជំងឺរាតត្បាតកូវីដ-១៩ ។ ទង្វើមនុស្សធម៌នេះ ត្រូវបានសហគមន៍អន្តរជាតិកោតសរសើរ ដោយចាត់ទុកកម្ពុជាថាជា **"ប្រទេសតូច ដែលមានបេះដូងធំ"** ។ កម្ពុជាបានផ្តល់ម៉ាស់ និងសម្ភារៈវេជ្ជសាស្ត្រដល់ប្រទេសឡាវ មីយ៉ាន់ម៉ា និងទីម័រខាងកើតដើម្បីចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងជំរុញការចរចាជាមួយប្រទេសជិតខាងដើម្បីថែរក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់ លើកកម្ពស់ចំណងមិត្តភាពជាប្រពៃណី និងវិបុលភាពរួម ក៏ដូចជាប្រឹងប្រែងដោះស្រាយបញ្ហាព្រំដែនដែលសេសសល់ដោយសន្តិវិធី ឈរលើមូលដ្ឋានច្បាប់អន្តរជាតិ និងគោលការណ៍មិនកែប្រែខ្សែព្រំដែនជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ដើម្បីផលប្រយោជន៍ជាតិ និងប្រជាជន។ ការចូលរួមយ៉ាងសកម្មក្នុងការកសាងសហគមន៍អាស៊ាន និងលើកកម្ពស់មជ្ឈភាពអាស៊ាន តាមរយៈកិច្ចខិតខំសម្រេចតាមចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងផែនការលម្អិតក្នុងសសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន ព្រមទាំងចូលរួមពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងដៃគូសន្ទនាខាងក្រៅ។ ក្នុងនាមជាប្រទេសសម្របសម្រួលកិច្ចសន្ទានអាស៊ាន-ណូវែលហ្សេឡង់ (២០១៨-២០២១) កម្ពុជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងភាពជាដៃគូនេះ ដោយបានជំរុញឲ្យមានការអនុម័ត" សេចក្តីប្រកាសរួមចក្ខុ-វិស័យរបស់មេដឹកនាំអាស៊ាន-នូវែលហ្សេឡង់ស្តីពីខួបលើកទី៤៥ នៃទំនាក់ទំនងសន្ទនាអាស៊ាន-នូវែលហ្សេឡង់៖ កេរ្តិ៍ដំណែលនៃភាពជាដៃគូមួយ,អនាគតរួមគ្នាមួយ"។ការពង្រឹង និងពង្រីកទំនាក់ទំនងជាមួយគណបក្សនយោបាយក្នុង និងក្រៅតំបន់ ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី សំដៅបម្រើ និងការពារផលប្រយោជន៍ជាតិ និងប្រជាជន ក៏ដូចជាលើកមុខមាត់កម្ពុជាលើឆាកអន្តរជាតិ។ គណបក្សបានបំពេញតួនាទីគួរជាទីមោទនៈក្នុងនាមជាអនុប្រធាន នៃអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ (CDI-IDC) និងសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី (ICAPP) និងបន្តជំរុញការទូតសេដ្ឋកិច្ច និងការធ្វើពិពិធកម្មទីផ្សារអន្តរជាតិ ទាំងក្នុងក្របខណ្ឌពហុភាគី និងទ្វេភាគី។ កម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរី (FTA) កម្ពុជា-ចិន។ កម្ពុជាក៏បាននិងកំពុងចរចា FTA ជាមួយសាធារណរដ្ឋកូរ៉េ និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) និងបានផ្តួចផ្តើមលទ្ធភាពចរចា FTA រវាងកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ជាមួយប្រទេសហុងគ្រី។

ពាក់ព័ន្ធការទូតសេដ្ឋកិច្ច ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានថ្លែងថា ការទូតសេដ្ឋកិច្ច គឺជាឧបករណ៍សំខាន់មួយសម្រាប់រដ្ឋាភិបាលក្នុងការធ្វើ សមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោក តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីកាន់តែស៊ីជម្រៅ



ពិធីប្រកាសដាក់ឲ្យអនុវត្ត យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

និងទូលំទូលាយ ដើម្បីធ្វើពិពិធកម្មប្រភពកំណើនរបស់ខ្លួន ពង្រឹកសក្តានុពល និងទាញយកផលប្រយោជន៍ពេញលេញពីកាលានុវត្តភាពថ្មីៗ។យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចត្រូវមានលក្ខណៈមុតស្រួចនិងវាងវៃក្នុងការការពារ និងធានានូវការលើកកម្ពស់ផលប្រយោជន៍ជាតិនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់វិបុលភាពផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។ ការអនុវត្តគោលនយោបាយ "ការទូតសេដ្ឋកិច្ចប្រកបដោយភាពបត់បែន និងប៉ិនប្រសប់" គឺជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពទាំង៥នៃការដ្ឋានកំណែទម្រង់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដែលទទួលបានការគាំទ្រពីសម្តេចតេជោ នាយករដ្ឋមន្ត្រី។ ដូចនេះ ការទូតសេដ្ឋកិច្ចបានក្លាយជាយុទ្ធសាស្ត្រអាទិភាពថ្មីមួយទៀត ដើម្បីចូលរួមពង្រឹងជន្លល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងលើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ។ ការដាក់ចេញនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច មានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារការទូត។ គោលបំណងនៃយុទ្ធសាស្ត្រនេះរួមមានៈការជំរុញពាណិជ្ជកម្មអន្តរជាតិ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងការជំរុញលើកស្ទួយវិស័យទេសចរណ៍ និងវប្បធម៌របស់កម្ពុជា ។ យុទ្ធសាស្ត្រនេះ នឹងក្លាយជាមាគ៌ាសម្រាប់អ្នកការទូតប្រើប្រាស់ក្នុងការអនុវត្តការងារការទូតសេដ្ឋកិច្ចឲ្យចំគោលដៅ និងមានប្រសិទ្ធភាព ។ **សម្តេចតេជោ ហ៊ុន សែន** គូសបញ្ជាក់ថា **"ការទូតសេដ្ឋកិច្ច"** គឺជាអាទិភាពសម្រាប់គោលនយោបាយការបរទេសកម្ពុជា ដោយមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើពិពិធកម្មប្រភពកំណើន និងដៃគូសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ការទូតសេដ្ឋកិច្ចនឹងជួយឲ្យកម្ពុជារក្សាបាននូវថាមភាព និងវិបុលភាពសេដ្ឋកិច្ច ក៏ដូចជាការលើកកម្ពស់កិត្យានុភាព និងតួនាទីរបស់កម្ពុជាលើឆាកអន្តរជាតិ។

ក្នុងឆ្នាំ២០២០ សភាពការណ៍អន្តរជាតិ បានបន្តវិវត្តប្រកបដោយភាពស្មុគស្មាញ ប្រែប្រួលឆាប់រហ័ស ពិបាកប៉ាន់ស្មាន និងមានហានិភ័យខ្ពស់ដែលបង្កឡើងដោយការប្រកួតប្រជែងរវាងមហាអំណាច គួបផ្សំនឹងបញ្ហាប្រឈមនៃសន្តិសុខមិនប្រពៃណីដែលកាន់តែធ្ងន់ធ្ងរ ។ កត្តាទាំងពីរនេះ មានភាពប្រទាក់ក្រឡាគ្នា ដែលធ្វើឲ្យស្ថានការណ៍ពិភពលោកកាន់តែមានភាពគ្រោះថ្នាក់ ហើយបានពន្លឿនការលេចជារូបរាងឡើងនៃសណ្តាប់ធ្នាប់អន្តរជាតិថ្មីមួយ ជំនួសសណ្តាប់ធ្នាប់ក្រោយសង្គ្រាមលោកលើកទី២ ដែលជាមូលដ្ឋានសារវន្តនៃសន្តិភាព និងវិបុលភាពពិភពលោកអស់រយៈពេលជាង៧០ឆ្នាំកន្លងមកនេះ។ បន្ថែមលើបញ្ហាប្រឈមសកលដែលមានស្រាប់ ដូចជាឧក្រិដ្ឋកម្មឆ្លងដែន ភេរវកម្ម និងអំពើហិង្សាជ្រុលនិយម ការប្រែប្រួលអាកាសធាតុ និងអសន្តិសុខស្បៀងនោះ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឲ្យពិភពលោកស្ថិតក្នុងគ្រោះមហន្តរាយ។

ក្នុងកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអង្គការសហប្រជាជាតិ លើកទី៧៥ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងថា ពិភពលោកកំពុងប្រឈមនឹងការគំរាមកំហែងខ្ពស់មិន ធ្លាប់ជួបប្រទះក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយ បង្កឡើងដោយឥទ្ធិពលរួមបញ្ចូលគ្នានៃបញ្ហាជាច្រើនរួមមានលទ្ធភាពឈានទៅរក សង្គ្រាមត្រជាក់បែបថ្មី ដែលអាចនាំឱ្យមានការផ្លាស់ប្តូរយ៉ាងស៊ីជម្រៅ ក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយជាសកល ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន បញ្ហាភេរវកម្មមិនមែនរដ្ឋ និងភាពអត់ឃ្លានទុក្ខវេទនានិងការកេងប្រវ័ញ្ចដែលធ្វើឱ្យមនុស្សរាប់លាននាក់រងគ្រោះ។ល។ អ្វីដែលពិភពលោកកំពុងប្រឈម គឺការផ្លាស់ប្តូរមិនអាចបកក្រោយទៅរកប្រព័ន្ធពហុប៉ូលដែលត្រូវបានលេចឡើងតាមរយៈការប្រកួតប្រជែងឈានទៅរកអភិរភាពដ៏តានតឹងរវាងមហាអំណាចធំៗ អមជាមួយនឹងការដើរបឡើងនៃមហាអំណាចថ្នាក់កណ្តាលនានា ដែលបោះជំហានយ៉ាងលឿនឆ្ពោះទៅជួរមុខនៃនយោបាយតំបន់។ ស្ថិរភាព និងវិបុលភាពរយៈពេលវែងបំផុត ក្នុងសម័យទំនើបនេះ ដែលកើតចេញពីសណ្តាប់ធ្នាប់អន្តរជាតិបង្កើតឡើងក្នុងឆ្នាំ ១៩៤៥ នោះ កំពុងទទួលរងភាពរង្គោះរង្គើយ៉ាងខ្លាំង ព្រោះគុណតម្លៃជាមូលដ្ឋានដែលជាគ្រឹះនៃសណ្តាប់ធ្នាប់នេះក៏ដូចជាគោលការណ៍ស្នូលនៃច្បាប់អន្តរជាតិត្រូវបានគេរំលោភបំពាននិងលែងគោរព។ និន្នាការឯកតោភាគីនិយម និងការប្រើកម្លាំងបាយគាបសង្កត់ប្រទេសទន់ខ្សោយកំពុងតែកើនឡើង ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់អន្តរជាតិ និងវិធានពហុភាគីនិយម។ ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងត្រូវបានគេប្រើប្រាស់ដោយឥតញញើត និងធ្វើឡើងក្នុងកម្រិតមួយ ដែលបំផ្លិចបំផ្លាញគោលការណ៍មូលដ្ឋាននៃធម្មនុញ្ញអង្គការសហប្រជាជាតិ ជាអាទិ៍ សិទ្ធិស្វ័យសម្រេច និងអធិបតេយ្យជាតិ។ ក្នុងបរិបទនេះ ការបំផ្លាញសណ្តាប់ធ្នាប់អន្តរជាតិ គឺជាមូលហេតុនៃក្តីបារម្ភដ៏ធំធេងរបស់យើង។ ទន្ទឹមនេះ លទ្ធភាពនៃការកើតឡើងនូវ **"សង្គ្រាមត្រជាក់បែបថ្មី"** ក៏បានក្លាយជាកង្វល់ដ៏ចម្បងមួយទៀត ព្រោះថា ប្រទេសកម្ពុជា ដ៏តូចមួយនេះធ្លាប់បានបង់ថ្លៃយ៉ាងដំណាំ ដោយសារជម្លោះសង្គ្រាមត្រជាក់ការខ្វែងគំនិតគ្នាផ្នែកមនោគមវិជ្ជា និងការប្រកាន់តរិយាបថជាតិនិយមជ្រុល។ ហេតុនេះ យើងត្រូវតែច្រានចោលយ៉ាងដាច់អហង្ការ រាល់ការប៉ុនប៉ងណាមួយដែលនាំទៅរកការសាដានៃប្រវត្តិសាស្ត្រ។

ឆ្លើយតបទៅនឹងបរិបទស្មុគស្មាញនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងផ្តោតលើការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពដូចតទៅៈ បន្តអនុវត្តនយោបាយការបរទេសមួយដែលផ្អែកលើគោលការណ៍រឹងមាំតែទន់ភ្លន់បត់បែនស្របតាមការវិវត្តនៃភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រ ដែលការពារ និងបម្រើផលប្រយោជន៍ជាតិ ការពារឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី អព្យាក្រឹត សន្តិភាព ស្ថិរភាព និងបង្កលក្ខណៈអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ រក្សាការប្រុងប្រយ័ត្នចំពោះការជ្រៀតជ្រែក

តទៅទំព័រ ២៧

ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីកំណើនសេដ្ឋកិច្ចជាតិក្នុងដំណាក់កាលកូវីដ-១៩

គម្រោងសាងសង់ផ្លូវជាតិលេខ៣ ចោមចៅ-បែកគុស-ទីរួមខេត្តកំពត

*ឯកឧត្តម **ស៊ុន ចាន់ថុល** អញ្ជើញចុះពិនិត្យលទ្ធភាពសម្រាប់ដាក់ឱ្យដំណើរការជាបណ្តោះអាសន្នស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១*

ទោះបីកម្ពុជាកំពុងប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែគិតគូរ និងយកចិត្តទុកដាក់លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាដើម្បីសម្រួលដល់ការរស់នៅ និងបង្កើនប្រាក់ចំណូលគ្រួសាររបស់បងប្អូនប្រជាពលរដ្ឋផងដែរ។

តើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជារឿងចាំបាច់សម្រាប់កម្ពុជាបែបណា?

រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននិងកំពុងធ្វើសកម្មភាពយ៉ាងសកម្មក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស ដើម្បីសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងវិស័យដឹកជញ្ជូន។ ការកែលម្អនឹងត្រូវធ្វើទៅលើផ្នែកជាច្រើនតាមផ្លូវជាតិនិងផ្លូវខេត្ត ដែលជាលទ្ធផលពិតជាបានជួយកាត់បន្ថយថ្លៃចំណាយលើការដឹកជញ្ជូន និងជួយសម្រួលដល់ខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងវិស័យ កសិកម្ម និងការអភិវឌ្ឍវិស័យទេសចរណ៍។ ការចំណាយលើការដឹកជញ្ជូននៅប្រទេសកម្ពុជានៅតែមានកម្រិតខ្ពស់នៅឡើយ ទោះបីជាមានភាពប្រសើរច្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ផ្លូវថ្នល់ជាមធ្យោបាយដឹកជញ្ជូននាំមុខគេនៅក្នុងប្រទេសហើយចាំបាច់ត្រូវមានការវិនិយោគច្រើន ជាពិសេសនៅតាមតំបន់ជនបទ។ ផ្លូវជនបទមានជាង៧៥ភាគរយ នៃបណ្តាញផ្លូវសរុបទូទាំងប្រទេស ប៉ុន្តែមានតែ៥ភាគរយប៉ុណ្ណោះដែលជាផ្លូវក្រាលកៅស៊ូ។ ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យមានភ្លៀងនិងទឹកជំនន់ធំៗ បង្កហានិភ័យខូចខាតកាន់តែខ្លាំងដល់ប្រព័ន្ធផ្លូវនៅជនបទ។ ការវិភាគអំពីស្ថានភាពប្រើប្រាស់របស់ផ្លូវជនបទបានបង្ហាញថា ក្នុងរដូវទឹកជំនន់ជាង ២៦ភាគរយ នៃប្រជាជន រស់នៅក្នុងតំបន់របស់គម្រោងប្រឈមនឹងហានិភ័យគ្មានផ្លូវប្រើប្រាស់សម្រាប់ទៅរកសេវាបន្ទាន់ផ្នែកសុខាភិបាលនិងសាលារៀន។ ក្រៅពីនោះប្រជាជន ១៨ភាគរយ ទៀតត្រូវចំណាយពេល ៣០នាទីឬច្រើនជាងនេះសម្រាប់ធ្វើដំណើរទម្រាំទៅដល់មន្ទីរពេទ្យដែលជាស្ថានភាពប្រឈមនឹងភាពស្លាប់រស់មួយ។ ដូចដែលយើងដឹងហើយថា ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ គឺដើម្បីពង្រីកសសៃឈាមសេដ្ឋកិច្ច ក៏ដូចជាការចូលរួមចំណែកកាត់ថ្លៃ ធ្វើដំណើររបស់ប្រជាពលរដ្ឋ និងវិស័យដឹកជញ្ជូន ដើម្បីឈានដល់ការប្រកួតប្រជែងក្នុងតំបន់ទៀតផង ។ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹងជញ្ជូន បានថ្លែងថា បច្ចុប្បន្នរដ្ឋាភិបាលកម្ពុជាកំពុងប្រឹងប្រែងក្នុងការកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់នៅគ្រប់ទីកន្លែងព្រមជាមួយនឹងការបន្តរៀបចំបើកច្រកទ្វារ ព្រំដែនជាបន្តបន្ទាប់។ នៅពេលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងកន្លែងឆ្លងកាត់ទំនិញមានភាពងាយស្រួល វានឹងរួមចំណែកជួយលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិកម្ពុជាបានមួយចំណែកបន្ថែមទៀត"។ ក្នុងមហិច្ឆតា ប្រែក្លាយមុខមាត់ប្រទេសលើឆាកអន្តរជាតិព្រមទាំងបង្កើនកម្រិតប្រាក់ចំណូលក្នុងសេដ្ឋកិច្ចជាតិនោះ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗបានលេចឡើងជាបន្តបន្ទាប់ទោះបីសេដ្ឋកិច្ចពិភពលោក កំពុងធ្លាក់ក្នុងបរិបទនៃការឆ្លងរាលដាលជំងឺកូវីដ១៩ ក៏ដោយ។

ឯកឧត្តម **ស៊ុន ចាន់ថុល** បានថ្លែងថា **"ទោះបីជំងឺកូវីដ ១៩ កំពុងបន្តការីករាលដាលក៏រដ្ឋាភិបាលមិនបានផ្អាក ឬលុបចោលគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗណាមួយនោះទេ"**។ រដ្ឋាភិបាលមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលជាកត្តាដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ឲ្យមានការីកចម្រើន"។ លោក **ច្រឹក សុខនីម** ប្រធានសមាគមភ្នាក់ងារ និងវាយតម្លៃអចលនវត្ថុកម្ពុជាបានឱ្យដឹងថា ការដាក់ចេញគម្រោង អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលនាពេលកន្លងមកនេះ គឺជាសញ្ញាមួយល្អដែលជំរុញវិស័យនានាមានការីកចំរើនរួមជាមួយនឹងវិស័យអចលនទ្រព្យផងដែរ។

ឯកឧត្តម **ង៉ាស៊ីម សូរិយា** អ្នកនាំពាក្យក្រសួងសាធារណការនិងដឹកជញ្ជូនបានឲ្យដឹងថា មកដល់ពេលនេះ បើទោះបីមានវិបត្តិ

ជំងឺ Covid-19 ក៏គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ដែលបានអនុវត្តកាលពីកន្លងមកនេះ នៅតែដំណើរការធម្មតា។ គម្រោងវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ភាគច្រើនគឺតាមរយៈកម្ចីហិរញ្ញប្បទាន និងសម្បទានដោយប្រទេសជាដៃគូអភិវឌ្ឍន៍របស់កម្ពុជាតាមរយៈការបញ្ជូនក្រុមហ៊ុនសាងសង់របស់ខ្លួនមកកាន់កម្ពុជា ដូចជា ចិន ជប៉ុន កូរ៉េ និងប្រទេសមួយចំនួនទៀត។ ឯកឧត្តមបណ្ឌិត **ម៉ី កល្យាណ** ទីប្រឹក្សាជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិបានថ្លែងថា ហេដ្ឋារចនាសម្ព័ន្ធជាបញ្ហាប្រឈមធំមួយ ក្នុងចំណោមបញ្ហាប្រឈមជាច្រើនទៀត ដែលរដ្ឋាភិបាលត្រូវដោះស្រាយ និងវិនិយោគ ក្នុងរយៈពេលវែង ព្រោះវាជាផ្នែកមួយនៃការប្រកួតប្រជែងរបស់កម្ពុជា ជាមួយខ្លួនឯងផង និងជាមួយបណ្តាប្រទេសក្នុងតំបន់ផង ។ ការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធត្រូវចំណាយប្រាក់ច្រើនប៉ុន្តែវាជារឿងចាំបាច់ត្រូវតែដោះស្រាយដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាទៅកាន់កម្រិតថ្មីមួយទៀត"។ ជាក់ស្តែង ក្រុមហ៊ុនសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ កំពុងវិវត្តន៍ជាវិជ្ជមាន ។ នៅក្នុងគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ បច្ចុប្បន្ននេះបាននិងកំពុងសាងសង់ យ៉ាងសកម្ម និងឈានទៅរកបញ្ចប់តាមផែនការ។ គម្រោងនេះវិនិយោគដោយក្រុមហ៊ុនសាធីវកម្មស្ពាន និងថ្នល់នៃប្រទេសចិន (China Road and Bridge)តាមរយៈ ក្រុមហ៊ុន Cambodian PPSHV Expressway Co., Ltd ត្រួតពិនិត្យ និងផ្តល់ការប្រឹក្សាបច្ចេកទេសសាងសង់ ដោយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស Minconsult SDN BHD ដោយប្រើប្រាស់ថវិកាវិនិយោគប្រមាណជិត ២.០០០លាន ដុល្លារអាមេរិក និងប្រើប្រាស់ថវិកាបដិភាគដែលជាហិរញ្ញប្បទានឥតសំណងពិសេសរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិនប្រមាណ ១៥០ លានដុល្លារ អាមេរិក។ ការសាងសង់ផ្លូវល្បឿនលឿនជាប្រវត្តិសាស្ត្រនេះ នឹងត្រូវប្រើរយៈពេលសាងសង់ចំនួន៤៨ខែ ដោយគិតចាប់ផ្តើមពីខែមីនា ឆ្នាំ២០១៩ និងបញ្ចប់នៅខែមីនា ឆ្នាំ២០២៣។ គិតត្រឹមខែមករា ឆ្នាំ២០២១ ការសាងសង់ផ្លូវល្បឿនលឿនពីរាជធានី ភ្នំពេញទៅដល់ខេត្តព្រះសីហនុក្រោមលក្ខខណ្ឌកិច្ចសន្យាសាងសង់- អាជីវកម្ម-ផ្ទេរ (BOT)សម្រេចបាន ៣១,១៩%

នៅក្នុងដំណាក់នៃវិបត្តិជំងឺកូវីដ-១៩នេះក្រសួងមិនទាន់មានគម្រោងដែលត្រូវសម្ពោធដាក់ឱ្យដំណើរការឬបើកការដ្ឋានសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធធំៗ និងថ្មីៗនោះទេ ។ គម្រោងកែលំអរផ្លូវជាតិលេខ៧ ឥម្លៃ៣៦ លានដុល្លារអាមេរិកសាងសង់សម្រេចបាន ៨០ភាគរយហើយគម្រោងផ្លូវជាតិលេខ៧ មានប្រវែងសរុប ១៦៤គីឡូម៉ែត្រ ដោយ លើកកម្ពស់គុណភាពផ្លូវពី DBST ទៅជា AC ដែលចំណាយថវិកាសរុបប្រមាណ៣៦ លានដុល្លារអាមេរិកបានសាងសង់សម្រេចបានប្រមាណ ៨០%ហើយ។ អ្នកនាំពាក្យក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម **ខាស៊ឹម សូរិយា** បានឱ្យដឹងថា គម្រោងនេះ ត្រូវបានបែងចែកជា ៣ការដ្ឋានធំៗប្រើប្រាស់រយៈពេលសាងសង់ចំនួន ១៨ខែ និងរយៈពេលថែទាំចំនួន ៣៦ ខែ សាងសង់ ដោយក្រុមហ៊ុនចិន ត្រួតពិនិត្យ លក្ខណៈបច្ចេកទេសដោយក្រុមហ៊ុនកូរ៉េ ។ កន្លងមកនេះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានប្រកាសសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣ គម្រោង បន្ថែមទៀត រួមមានផ្លូវលេខ៤១ តភ្ជាប់ផ្លូវលេខ៤ ទៅកំពត ផ្លូវលេខ៣១ និងផ្លូវ លេខ៣៣ នៅខេត្តកំពត។ គម្រោងសាងសង់ផ្លូវទាំង ៣ខ្សែនេះនឹងត្រូវស្នើសុំ កម្ចីថវិកាពីរដ្ឋាភិបាលចិន។ "គម្រោងទាំងនេះ នឹងសុំខ្ចីថវិកាពីរដ្ឋាភិបាលចិន"។ កម្ពុជាជាប្រទេសមួយក្នុង ចំណោមប្រទេសដែលកំពុងអភិវឌ្ឍន៍ ដោយក្នុងនោះប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការសាងសង់ ដែលមាន ទាំងគម្រោងកំពុងដំណើរការសាងសង់ និងគម្រោងគ្រោងទុកទៅថ្ងៃខាងមុខផងដែរ។ ក្នុងនោះផ្លូវជាតិ ផ្លូវដែក ផ្លូវអាកាស ស្ពានអាកាស ស្ពានឆ្លងកាត់ទន្លេជាដើមត្រូវបានរដ្ឋយកចិត្តដាក់ក្នុងការសាងសង់ដើម្បីពន្លឿនដល់ការ អភិវឌ្ឍប្រទេស។ ខណៈនេះដែរយើងនឹងលើកយកគម្រោងសាងសង់ផ្លូវជាតិ និងស្ពានចំនួន ៤ គម្រោងដែល រដ្ឋាភិបាលបានបង្ហើបកាលពីពេលកន្លងទៅដែលរួមមាន ៖

១. ផ្លូវជាតិតភ្ជាប់ខេត្តកំពតចេញទៅផ្លូវជាតិលេខ៤

ក្នុងកម្មវិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពតនាពេលកន្លងទៅ **សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថាក្រៅពីផ្លូវជាតិលេខ៣យើងមានផ្លូវជាតិ៤១ដែលឆ្ពោះមកខេត្តកំពត ហើយយើងកំពុងតែរៀបចំបណ្តាញផ្លូវមួយទៀតដើម្បីតភ្ជាប់ខេត្តកំពតចេញទៅ ផ្លូវជាតិលេខ០៤ ដែលស្ថិតនៅម្តុំ ពេជ្រនិល ក៏ប៉ុន្តែមិនទាន់បានបញ្ជាក់នៅឡើយទេថា ផ្លូវមួយខ្សែនោះមានទីតាំងនៅកន្លែងណា ព្រោះត្រូវការពិនិត្យ មើលផែនទីជាមុនសិន។

២. ស្ពានតភ្ជាប់ពីខេត្តកំពង់ឆ្នាំងទៅខេត្តកំពង់ធំ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានប្រកាសសាងសង់ស្ពានឆ្លងទន្លេសាប ដែលមានប្រវែង ៣៩០០ ម៉ែត្រ និងផ្លូវប្រវែងជាង ៥៧ គីឡូម៉ែត្រ តភ្ជាប់ពីខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ ចំពោះការសាងសង់ស្ពាននេះគឺដើម្បីសម្រួលដល់ការធ្វើដំណើរចំណេញពេលវេលា និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ ។ ស្ពាននេះវែងជាងគេនៅប្រទេសកម្ពុជា ឆ្លងកាត់ដៃ ទន្លេទាំង៣ ក្នុងខេត្តកំពង់ឆ្នាំង គឺទន្លេផ្សារក្រោម, ទន្លេជ្រោយ បុស្ស និងទន្លេកំពង់ហាវ។

៣. ស្ពានឆ្លងកាត់ទន្លេនៅខេត្តក្រចេះ

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានឲ្យដឹងថា ការសាងសង់ស្ពានចំនួន ១ខ្សែដែលមានទីតាំងក្នុងខេត្តក្រចេះ នឹងត្រូវបើកការដ្ឋានសាងសង់ក្នុងពេល ដ៏ខ្លីខាងមុខ ខណៈការសិក្សា និងការស្វែងរកថវិកាត្រូវបានបញ្ចប់។ ឯកឧត្តមបានបញ្ជាក់បន្ថែមថា៖ **«យើងកំពុងសិក្សាស្ពានឆ្លងកាត់ទន្លេមេគង្គ ហើយយើងត្រៀមបើកការដ្ឋានស្ពាន ឆ្លងកាត់ទន្លេមេគង្គនៅក្រចេះនេះដែរ»**។

៤. ស្ពានឆ្លងកាត់ទន្លេបាសាក់ពីព្រែកប្រាមកកាន់ចាក់អង្រែលើ

នាពេលថ្មីៗនេះរដ្ឋបាលរាជធានីភ្នំពេញ បានបង្ហើបអំពីគម្រោងសាងសង់ ស្ពានថ្មី១ ទៀតឆ្លងកាត់ទន្លេបាសាក់ ដែលភ្ជាប់ពីសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ មកសង្កាត់ចាក់អង្រែលើខណ្ឌមានជ័យ រាជធានីភ្នំពេញដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍នៅតំបន់ច្បារអំពៅ និងតំបន់ស្ពានអាកាសក្បាលថ្នល់។ ខណៈបច្ចុប្បន្នរដ្ឋបាលរាជធានីភ្នំពេញ ក៏បានបង្កើតក្រុមការងារមួយ ដើម្បីចុះសិក្សាគម្រោង និងផលប៉ះពាលដល់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ រួចហើយដែរ។

គម្រោងធំៗនៅកម្ពុជា នៅចាំតែថ្ងៃបើកការដ្ឋាន

កាលណាបើនិយាយពីគម្រោងធំៗនៅកម្ពុជា កំពុងតែសាងសង់គេប្រាកដជាគិតទៅដល់ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ព្រលាន

តទៅទំព័រទី ២៥

ទស្សនភាព និងបញ្ហាប្រឈមនៃវិស័យការងារ ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩

*ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** ដឹកនាំគណៈប្រតិភូជួបប្រជុំជាមួយគណៈកម្មការទី៨ នៃរដ្ឋសភា ដើម្បីធ្វើរបាយការណ៍សង្ខេបទាក់ទងនឹងវឌ្ឍនភាពវិស័យការងារ និងបញ្ហាប្រឈមក្នុងដំណាក់កាលកូវីដ-១៩*

ជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោក ហើយការកើនឡើងនៃវិបត្តិនេះ កំពុងបង្កផលប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍមិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានប៉ះពាល់ដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៃបណ្តាប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរ។ ដូចគ្នានេះដែរ បណ្តាប្រទេសសមាជិកអាស៊ានទាំងអស់រាប់ទាំងកម្ពុជាផង ក៏កំពុងទទួលរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីជំងឺកូវីដ-១៩ដូចគ្នា ដែលនាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរនៃការធ្វើដំណើរការពាណិជ្ជកម្ម និងការវិនិយោគជាដើម ។

តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា នៅក្នុងឆ្នាំ២០២០ កន្លងទៅនេះ មានសហគ្រាសចំនួន ១ ៣៥៦ទីតាំងបានបិទលែងដំណើរការ ដោយមានកម្មករនិយោជិតបាត់បង់ការងារចំនួន ១០៨.៨២៥នាក់ ។ បើតាមការវាយតម្លៃផលប៉ះពាល់លើវិស័យការងាររបស់កម្មករនិយោជិត សេដ្ឋកិច្ចក្នុងប្រព័ន្ធគឺស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងបានឆ្លងកាត់នូវដំណាក់កាលលំបាកបំផុតរួចមកហើយ ។ តួយ៉ាង ការព្យួរកិច្ចសន្យាការងាររបស់រោងចក្រ សហគ្រាស នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍បានថយពីចំណុចកំពូលនៅក្នុងខែមិថុនា ឆ្នាំ២០២០ ដែលនៅពេលនោះមានរោងចក្រសហគ្រាសចំនួន៤៣៣ មានកម្មករនិយោជិតចំនួន ១៥៣.៣៣៦នាក់ បានព្យួរកិច្ចសន្យាការងារ។ ប៉ុន្តែគិតមកដល់ដំណាច់ខែធ្នូ ឆ្នាំ២០២០ មានរោងចក្រ សហគ្រាសត្រឹមចំនួន១៥០ ដែលស្មើមានកម្មករនិយោជិតចំនួន ២៣៦ ៨២នាក់ប៉ុណ្ណោះកំពុងព្យួរកិច្ចសន្យាការងារ ។

